*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

# សមិទ្ធផល និងឧបសគ្គ ក្នុងកសាងសមត្ថភាព និង ការអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិតាមរយៈការផ្តល់ អាហារូបករណ៍ដល់គ្រូបង្រៀននៅជនបទ

OUM Ravy and SOK Serey
Royal University of Phnom Penh, Russian Federation Boulevard, Toul Kork,
Phnom Penh, Cambodia
Corresponding Author: OUM Ravy (oumravy@yahoo.com)

**To cite this article:** Oum, R. and Sok, S. (2021) **សមិទ្ធផល និងឧបសគ្គ ក្នុងកសាងសមត្ថភាព និងការអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP-ADB) តាមរយៈការផ្តល់អាហារូបករណ៍ដល់គ្រូបង្រៀននៅជនបទ**. *Journal of Basic and Applied Research (CJBAR), 3(1-1)*, 1–11.

## សង្ខិតន័យ

គោលបំណងចម្បងនៃការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ពីគរុកោសល្យ (Pre-service Training) ដែលផ្តល់ដោយវិទ្យាស្ថានជាតិអប់រំក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP-ADB) ដោយផ្តោត លើចំណេះដឹងដែលទទួលបាន គុណភាពសិក្សា និងផែនការត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញតាមកិច្ចសន្យា។ ការវិភាគសម្រាប់ការសិក្សានេះមានទាំងគុណវិស័យ និងបរិមាណវិស័យ ហើយទិន្នន័យបានប្រមូលពីគរុនិស្សិតដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំក្រោមគម្រោង USESDP-ADB ដែលបច្ចុប្បន្នពួកគាត់កំពុងបម្រើការងារនៅតាមវិទ្យាល័យនានា ក្នុងខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ព្រះវិហារ បន្ទាយមានជ័យ ត្បូងឃ្មុំ ក្រចេះ និងកោះកុង។ សម្រាប់ទិន្នន័យបរិមាណវិស័យ ត្រូវប្រើប្រាស់កម្រងសំណួរបែប Structured ដែលបានប្រមូលពីគរុនិស្សិតចំនួន 108នាក់ (ស្រី43នាក់ ប្រុស65នាក់)។ ចំណែកឯកម្រងសំណួរបែប Unstructured បានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យគុណវិស័យ ជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នាយកវិទ្យាស្ថានជាតិអប់រំ និងអ្នកសម្របសម្រួលកម្មវិធី USESDP-ADB នៅវិទ្យាស្ថានជាតិអប់រំ។ រីឯកម្រងសំណួរបែប semi-structured ក៏បានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីសាស្ត្រាចារ្យដែលបង្រៀននៅវិទ្យាស្ថានជាតិអប់រំផងដែរ។

ការសិក្សាបានបង្ហាញឱ្យឃើញថា: (១) គរុនិស្សិតមានភាពពេញចិត្តខ្ពស់លើកម្មវិធីសិក្សា លើកលែងតែសូចករទាក់ទងនឹងឱកាសហាត់ការ ពួកគាត់ពេញចិត្តត្រឹមតែមធ្យម។ (២)គរុនិស្សិត ជាបុរស និងស្ត្រីមានទស្សនៈវិជ្ជមាន និងពេញចិត្តខ្លាំងលើការទទួលបានចំណេះដឹង (knowledge) ជំនាញ (skill) និងភាពស្ទាត់ជំនាញលើការងារ (competency)។ កត្តាដែលធ្វើឱ្យចំណេះដឹងកើនរួមមាន

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

សមត្ថភាពយល់ដឹង (Cognitive capacity) និង ការចូលរួមការងារសង្គម(social capacity) ហើយកត្តាដែលធ្វើឱ្យមានភាពស្ទាត់ជំនាញលើការងារ (competency) កើនរួមមានខ្លឹមសារបង្រៀន វិធីសាស្ត្របង្រៀន និងការតម្រង់ទិសនិងការជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវ។ (3) វាមានទំនាក់ទំនងរវាងការស្នើសុំកែកិច្ចសន្យា និងការមិនអាចទទួលយកបាននូវលក្ខខណ្ឌក្នុងកិច្ចសន្យា (4)ក្នុង១ខែ គរុនិស្សិតក្នុងពេលសិក្សានៅវិទ្យាស្ថានជាតិអប់រំ ទទួលបាន80ម៉ឺនរៀលពីគម្រោង ហើយប្រាក់ឧបត្ថមនេះវាតិចជាងការចំណាយប្រចាំខែជាក់ស្តែងខ្លាំងណាស់(94ម៉ឺនរៀលក្នុង១ខែ)។ (5) គរុនិស្សិតទទួលបានប្រាក់ខែជាមធ្យម 1.1លានរៀល ដែលជាចំនួនច្រើនជាង ការផ្គត់ផ្គង់ការចាយវាយប្រចាំខែផ្ទាល់ខ្លួន(4.9សែនរៀល)។ ប៉ុន្តែគរុនិស្សិត ចង់បានប្រាក់បៀវត្សន៍រហូតដល់1.6លានរៀលក្នុង១ខែ ប្រសិនបើចង់អោយពួកគាត់ផ្តោតតែលើការបង្រៀនតែមួយគត់។ ចំនួនប្រាក់បៀវត្សន៍ដែលចង់បានប្រហែលជាចំនួនប្រាក់ខែដែលអាចផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារទាំងមូលពួកគាត់បានល្មម។

## សាវតានៃការស្រាវជ្រាវ

ការពង្រឹង និងការកសាងសមត្ថភាពរបស់គ្រូបង្រៀនជាយន្តការមួយដែលអាចធានាបាននូវការផ្លាស់ប្តូរប្រកបដោយចីរភាពនិងស្ថិតស្ថេរ ក្នុងការលើកស្ទួយវិស័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍ប្រទេសជាតិ។ បើយោងទៅតាម Reimers (2020) ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនទ្រង់ទ្រាយធំមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំគ្រូឱ្យដឹកនាំការសិក្សារបស់សិស្សដើម្បីស្វែងយល់អោយបានស៊ីជម្រៅនិងក្នុងការអភិវឌ្ឍជំនាញចំណេះដឹង និងសង្គមអោយបានទូលំទូលាយ។ ជារួមទោះបីជា វាមានទំនាក់ទំនងរវាងគុណភាពគ្រូបង្រៀន និងបង្កើនចំនេះដឹង និងទទួលបានបទពិសោធន៍របស់សិស្ស (Darling-Hammond et al. 2005; UNESCO, 2014) ក៏ដោយ តែ Fennessy (1998) បានកត់សំគាល់ឃើញថា ប្រទេសមួយចំនួនមិនសូវមានការយកចិត្តទុកដាក់ និងផ្តោតលើការការផ្លាស់ប្តូរប្រព័ន្ធអប់រំ។ ជាលទ្ធផលការវិនិយោគទន់លើការលើកម្មវិធីពង្រីកចំណេះក៏នៅមានកំណត់ដែរ(KAPE, 2016)។ការស្រាវលទ្ធផលការជ្រាវរបស់ Beeby (1980) បានរកឃើញថាភាពខ្វះខាតរបស់គ្រូបង្រៀនដែលមានគុណភាពអាចបណ្តាលអោយការផ្លាស់ប្តូជាវិជ្ជមានឃឹតលើការអភិវឌ្ឍន៍វិស័យអប់រំ។ បើទោះជាកសាងសមត្ថភាពរបស់គ្រូបង្រៀន ជាជំរើសមួយសំរាប់ការបង្កើនគុណភាពបង្រៀន តែក៏មានជំរើសផ្សេងៗជាច្រើនទៀតក្នុងការពង្រឹងគុណភាពការអប់រំក្រៅពីផ្តល់ការបណ្តុះបណ្តាលបន្ថែមលើគ្រូបង្រៀនដែរ។ បើតាមការស្រាវជ្រាវបានបង្ហាញថាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនអាចធ្វើតាមរយៈ ជាការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព ភាពសមស្រប (Tatto, 2008) និងការផ្តល់ប្រាក់បៀវត្សន៍ខ្ពស់ (Darling-Hammond and Berry1988) ដើម្បីទាក់ទាញគ្រូបង្រៀនដែលមានគុណភាពខ្ពស់។ ក្នុងពេលជាមួយគ្នានេះដែរ ការជួយគ្នាទៅវិញទៅមក ការ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ផ្លាស់ប្ដូរបិសោធន៍ និងចំណេះដឹងក្នុចំណោមគ្រូបង្រៀនដូចគ្នាក៏ជាជំរើសមួយក្នុងពង្រឹងសមត្ថភាព និងគុណភាពការបង្រៀនដែរ (Hargreaves 2000)។

ទោះបីជាការបណ្ដុះបណ្ដាលគ្រូបង្រៀនមានសារៈសំខាន់យ៉ាងណាក៏ដោយ តែការទទួលបានការពង្រឹងសមត្ថភាពរបស់ពួកគាត់នៅមានកំរិតពីព្រោះជាទូទៅគ្រូបង្រៀនពុំមានធនធានគ្រប់គ្រាន់ក្នុងការទទួលបានការពណ្ដុះបណ្ដាលដោយខ្លួនឯងទេ។ ដូច្នេះការផ្ដល់អាហារូបករណ៍អាហារូបករណ៍បានផ្ដល់នូវឱកាសសម្រាប់គ្រូបង្រៀន ជាច្រើនដើម្បីទទួលបានការអប់រំ។ បើគ្មានជំនួយពីប្រភពខាងក្រៅទេ គ្រូបង្រៀនអាចនឹងមានបញ្ហាក្នុងការចូលរៀនដើម្បីទទួលបានសញ្ញាបត្រ ដែលពួកគេត្រូវការដើម្បីចូលរួមជាកម្លាំងពលកម្មនិងក្លាយជាសមាជិកដែលចូលរួមចំណែកនៅក្នុងសង្គម។ ជាពិសេសនៅសាលាតាមជនបទក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា អាហារូបករណ៍សម្រាប់គ្រូបង្រៀនមានសារៈសំខាន់ណាស់ ពីព្រោះអាចទាក់ទាញនិងរក្សាវត្តមានគ្រូបង្រៀននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលបានរយៈពេលយូរអង្វែង។ ដើម្បីលើកទឹកចិត្តអោយគ្រូបង្រៀនអាចបន្តការបង្រៀនបានយូអង្វែងគឺជាបញ្ហាទូទាំងពិភពលោក (West & Jones, 2007) ចំណែកឯឱកាសទទួលបានវិញ្ញាបនបត្ររបស់គ្រូនៅតាមតំបន់ជនបទក៏នៅមានកម្រិតទាបដែរ (Grant, 2010)។

ជាងនេះទៅទៀត សហគមន៍ជនបទដែលត្រូវការគ្រូ និងសិស្សមានបំណងចង់ក្លាយជាគ្រូបង្រៀនគឺស្ថិតនៅក្នុងគុណវិបត្តិមួយដោយសារតែខ្វះជម្រើសអប់រំ។ នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីទសវត្សឆ្នាំ ១៩៨០ ការបណ្ដុះ បណ្ដាលគ្រូបង្រៀន (Pre-service Training)បានចាប់ផ្ដើម ផ្លាស់ប្ដូរពីការបណ្ដុះបណ្ដាលអាដហុក ដែលផ្ដល់ជូនក្នុងអំឡុងពេលវិស្សមកាលសាលារៀនទៅជាកម្មវិធីពេញម៉ោងរយៈពេល ១ ឬ២ ឆ្នាំ។ បើយោងតាម Tan and Ng (2012, p. 128) គ្រូបង្រៀននៅកម្ពុជាសព្វថ្ងៃមានសមត្ថភាពនិងទទួលបានការបណ្ដុះបណ្ដាលល្អប្រសើរ ដោយបានរៀនពីចំណេះដឹង ទ្រឹស្ដីនិងជំនាញថ្មីៗ។ អាស្រ័យហេតុនេះហើយ ការសិក្សាស្រាវជ្រាវពីសមិទ្ធផល និងឧបសគ្គ ក្នុងការបណ្ដុះបណ្ដាលគ្រូ (Pre-service Training) មានសារៈសំខាន់ណាស់ដើម្បីពង្រឹងវិស័យអប់រំនៅកម្ពុជា។

បើតាមការសិក្សារបស់ Phin (2014) បានបង្ហាញថាការបណ្ដុះបណ្ដាលគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ មានន័យថាមិនទាន់អាចធានាបានថាគ្រូបង្រៀនទាំងអស់មិនសមត្ថភាពគ្រប់គ្រាន់ និងគ្រប់គ្នាទូទាំងប្រទេសនៅឡើយទេ។ជាងនេះទៅទៀត ការបណ្ដុះបណ្ដាលនៅមិនមិនទាន់អាចពង្រឹងសមត្ថភាពគ្រូបង្រៀនអោយបានគ្រប់ជ្រុងជ្រោយ ក៏ដូចជាអាចបង្កើនសមត្ថភាពបានល្អនៅឡើយទេ។ ទោះបីជាមានការផ្ដល់ការបណ្ដុះបណ្ដាលដោយស្ថាប័នអន្តរជាតិក៏ដោយមួយចំនួនដែរ តែមិនទាន់អាចឆ្លើយតបតាមតំរូវការ និងឆ្លើយតបតាមតំរូវការ និងស្ថានភាពជាក់ស្ដែង នៅឡើយទេ(Fata, n.d.)។ ជាងនេះទៅទៀតគ្រូបង្រៀនក្នុងប្រទេសកម្ពុជាមិនសូវចូលចិត្តធ្វើការងារជាក្រុមទេ ការផ្លាស់ប្ដូរបទពិសោធន៍ ក៏ដូចជាការទទួលយកនូវយោបល់ក្នុងការស្ដាបនាពីគ្រូបង្រៀនដូចគ្នាក៍

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

មិនទាន់ធ្វើបាននៅឡើយទេ (Tan & Ng, 2012)។ ដើម្បីលើកស្ទួយគុណវុឌ្ឍន៍គ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយគ្រូបង្រៀននៅឆ្នាំ ២០១៤ ហើយក្រោយមកនៅឆ្នាំ ២០១៥ និងបានបង្កើតផែនការសកម្មភាពគោលនយោបាយបានចាប់ផ្តើម អនុវត្តពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ ។ ផែនការសកម្មភាព និហគោលនយោបាយនេះមានគោលបំណងទាក់ទាញបេក្ខជនដែលមានសមត្ថភាព ធ្វើឱ្យបានប្រសើរឡើងនូវជីវភាពរស់នៅ របស់គ្រូបង្រៀន រក្សាគ្រូមានលក្ខណៈសម្បត្តិ ជំនាញវិជ្ជាជីវៈ លើកកម្ពស់គុណភាពការបង្រៀន និងការបង្កើនសមត្ថភាពរបស់គ្រូបងរៀននាពេលបច្ចុប្បន្ន (Blanquat & Associates, 2016)។

ដើម្បីរួមចំណែក កសាងសមត្ថភាពរបស់គ្រូបង្រៀនក្នុងប្រទេសកម្ពុជា គំរោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ(USESDP-ADB) បានផ្តោតលើការកសាងសមត្ថភាពដល់គ្រូបង្រៀនដែលនៅខេត្តដាច់ស្រយាលចំនួន៧ ដូចជា កោះកុង ប៉ៃលិន ឧត្តមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី។ អាហារូបករណ៍(USESDP-ADB) បានផ្តល់ដល់គរុនិស្សិតដែលប្រលងចូលរៀនលើមុខវិជ្ជា ពត៌មានវិទ្យា ភាសារអង់គ្លេស ភាសាបារាំង គណិតវិទ្យា និងវិទ្យសាស្រ្ត ដូចជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និង វិទ្យាសាស្រ្តផែនដីនៅវិទ្យាស្ថានជាត់អប់រំ។ អាហារូបករណ៍(USESDP-ADB)ដែលមានចំនួន៥០០នាក់(ក្នុងនោះមាន៤០%ត្រូវតែជាគរុនិស្សិតស្រី)ត្រូវផ្តល់ជូនគរុនិស្សិតនៅវិត្យាស្ថានជាតិអប់រំ ក្នុងគំម្រោងរយៈពេលបួនឆ្នាំ ។ ដូច្នេះក្នុង១ឆ្នាំអាហារូបករណ៍ចំនួន១២៥នាក់បានជ្រើសរើសក្នុងចំណោមគរុនិស្សិតដែលដាក់ពាក្យរៀនលើមុនវិជ្ជា ពត៌មានវិទ្យា ភាសារអង់គ្លេស ភាសាបារាំង គណិតវិទ្យា និងវិទ្យសាស្រ្ត ដូចជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និង វិទ្យាសាស្រ្តផែនដី។ ក្នុងជុំទី១នៃការផ្តល់អាហារូបករណ៍ដែលបានចាប់ផ្តើមពីខែវិច្ឆកា ២០១៧ បានផ្តល់អោយគរុនិស្សិតចំនួន៦៧នាក់ (ក្នុងនោះមានស្រ្តីចំនួន ២៨នាក់)។ ក្នុងការជ្រើសរើសក្នុងជុំទីមួយ មានគរុនិស្សិតដែលបានដាក់ពាក្យតិចជាងចំនួនដែលបានរំពឹងទុក។ ចំនួននិស្សិតដែលបានដាក់ពាក្យមានចំនួនតិច ហើចំនួនអ្នកទទួលអាហារូបករណ៍មានចំនួនមិនគ្រប់ចំនួន។ ជាងនេះទៅទៀត គរុនិស្សិតចំនួន៥នាក់ដែលទទួលអាហារូបករណ៍(USESDP-ADB)មិនបានទៅបំរើការងារនៅខេត្តគោលដៅ ហើយពួកគាត់ក៏ត្រូវបានអនុញ្ញាត្តដោយក្រសួងអប់រំ និងកីឡាក្នុងកាផ្ទេរក្រុបខ័ណ្ឌទៅបង្រៀនសាលាផ្សេងផងដែរ (ADB, 2018)។

## គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ ពីបណ្តុះបណ្តាលគ្រូ (Pre-service Training) ដែលផ្តល់ដោយវិទ្យាស្ថានជាតិអប់រំក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិUSESDP ADB ដោយផ្តោតលើ ចំណេះដឹងដែលទទួលបាន គុណភាពសិក្សា និងផែនការត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញតាមកិច្ចសន្យា។ ការសិក្សានេះមានគោលបំណងដាក់លាក់ចំនួន៣ធំៗ។

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

- វាយតម្លៃចំណេះដឹង ជំនាញ និងសមត្ថភាពការងារដែលទទួលបានពីវគ្គបណ្តុះបណ្តាលគរុកោសល្យកម្រិតឧត្តម (បរិញ្ញា+១)
- វិភាគពី កម្មវិធីសិក្សា គុណភាពបង្រៀន និងការស្នាក់នៅរបស់គរុនិស្សិត ដែលទទួលបានអាហារូបករណ៍ក្រោមគម្រោងUSESDP-ADB
- សិក្សាពីទស្សនៈរបស់គរុនិស្សិតដែលបានបញ្ចប់ការសិក្សា និងគរុនិស្សិតដែលកំពុងសិក្សា និងពីវិសាលភាពកិច្ចសន្យា តម្រូវការ និងការលើកទឹកចិត្តដែលអាចអោយលោកគ្រូ អ្នកគ្រូត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញតាមកិច្ចសន្យា។

## វិធីសាស្ត្រស្រាវជ្រាវ

ការវិភាគសម្រាប់ការសិក្សានេះបានប្រើប្រាស់ទិន្ន័យទាំងគុណវិស័យ និងបរិមាណវិស័យ។ សម្រាប់ទិន្នន័យបរិមាណវិស័យ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបstructured ដើម្បីប្រមូលទិន្ន័យក្នុងចំណោមគរុនិស្សិតដែលបានបញ្ចប់កាសិក្សា ទាក់ទងនឹង ចំណេះដឹង ជំនាញ សមត្ថភាពការងារ កម្មវិធីសិក្សា គុណភាពបង្រៀន ការស្នាក់នៅរបស់គរុនិស្សិត វិសាលភាពកិច្ចសន្យា តម្រូវការ និងការលើកទឹកចិត្តដែលអាចឱ្យលោកគ្រូ អ្នកគ្រូត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញតាមកិច្ចសន្យា។ កម្រងសំណួរបែបunstructured បានប្រើប្រាស់ដើម្បីប្រមូលទិន្ន័យគុណវិស័យ ជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា អ្នកសម្របសម្រួលកម្មវិធីនៃវិទ្យាស្ថានជាតិអប់រំ មន្ត្រីគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិUSESDP ADB និងនាយកសាលា។ កម្រងសំណួរបែប semi-structured ក៏នឹងប្រើប្រាស់ដើម្បីប្រមូលទិន្ន័យពីសាស្ត្រាចារ្យដែលបង្រៀនតាមមុខវិជ្ជានីមួយៗនៅវិទ្យាស្ថានជាតិអប់រំដើម្បីស្វែងយល់ពីកម្មវិធីសិក្សា និងគុណភាពបង្រៀន ក៏ដូចជាចំណេះដឹង ជំនាញ និងសមត្ថភាពការងាររបស់គរុនិស្សិត។ ក្នុងការអង្កេត គរុនិស្សិតចំនួន ១០៨នាក់ត្រូវបានទាក់ទងក្នុងការធ្វើអង្កេត ដែលក្នុងនោះមានបុរស ៦៥ នាក់ និងស្ត្រីចំនួន៤៣ បានទាក់ទងធ្វើបទសំភាសន៍ (តារាងទី១)។

**តារាងទី១.** សំណាកគំរូក្នុងការប្រមូលទិន្ន័យ

| ល. | អ្នកឆ្លើយតប | ចំនួន |
|---|---|---|
| ១ | គរុនិស្សិតដែលបញ្ចប់ការសិក្សាជាបុរស | ៦៥ |
| ២ | គរុនិស្សិតដែលបញ្ចប់ការសិក្សាជាបុរស | ៤៣ |
| ៣ | សាស្ត្រាចារ្យដែលបង្រៀនតាមមុខវិជ្ជានីមួយៗនៅវិទ្យាស្ថានជាតិអប់រំ | ៥ |
| ៤ | ប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត | ៧ |
| ៥ | នាយកសាលា | ៥ |
| ៧ | អ្នកសម្របសម្រួលកម្មវិធីនៅវិទ្យាស្ថានជាតិអប់រំ | ១ |

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

| | | |
|---|---|---|
| ៨ | នាយកវិទ្យាស្ថានជាតិអប់រំ (NEI) | ១ |

ការអង្កេតជាគរុនិស្សិតដែលបានទទួលអាហារូបករណ៍(USESDP-ADB)ដោយប្រើកម្រងសំណួរបែបunstructured បានធ្វើឡើងដើយក្រុមស្រាវជ្រាវ នាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា នៅសាលាដែលគរុនិស្សិតទៅបង្រៀន ក្នុងខេត្ត កោះកុង ប៉ៃលិន ឧត្តមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី។ ការអង្កេតបែបself-admistered ត្រូវបានធ្វើឡើងដោយផ្តល់កម្រងសំណួរបែបunstructured ទៅអោយគរុនិស្សិតបំពេញផ្ទាល់។ ការប្រើប្រាស់វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យបែប ការអង្កេតបែបself-admistered អាចផ្តល់ឱកាស់ដល់គរុនិស្សិតបញ្ចេញយោបល់ដោយត្រង់ និងគ្មានលាក់លៀមនូវបញ្ហា ឬការប្រឈមដែលគរុនិស្សិតបានជួបប្រទះក្នុងពេលសិក្សា និងចេញទៅបំរើការងារងារតាមខេត្រគោលដៅ។ ជាងនេះទៅទៀតក្រុមការងារក៏បានប្រមូលទិន្នន័យពីគរុនិស្សិតតាមរយៈ telegram មានន័យថាក្រុមស្រាវជ្រាវបានផ្ញើកម្រងសំណួរបែបunstructured ដើម្បីដាក់ជូនពួកគាត់បំពេញ។

## ព័ត៌មានអ្នកឆ្លើយតប

ជារួមអ្នកឆ្លើយតស្ទើតែទាំងអស់(90.8%)បានបញ្ចប់ការសិក្សាបរិញ្ញប័ត្រ (រូបភាពទី ១)។ សមាមាត្រភាគរយអ្នកឆ្លើយតបជាស្ត្រី និងបុរសមានចំនួនស្មើគ្នា។

**រូបភាពទី១.** កំរិតអប់រំដែលទទួលបានរបស់អ្នកឆ្លើយតប



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ដោយសារមានការជ្រុំជ្រែង និងការជួយគាំទ្រទាំងថវិការ និងបច្ចេកទេស រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំយុវជននិងកីឡាបានរៀបចំផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនដែលបានប្រកាស់ដាក់អោយប្រើប្រាស់ នៅឆ្នាំ២០១៥ ដោយបានកំណត់ថាគ្រូបង្រៀនទាំងអស់នឹងមានបរិញ្ញាបត្រយ៉ាងតិចនៅឆ្នាំ ២០២០ ដើម្បីធានាសមត្ថភាពរបស់ពួកគេក្នុងការអប់រំ និងបណ្តុះបណ្តាលអ្នកជំនាញ (Blanquat & Associates, 2016)។ យោងទៅតាមការសំភាសន៍ជាមួយគរុនិស្សិតបានលើកការព្រួយបារម្ភថា ការទទួលបានចំណេះដឹងផ្នែកវិទ្យាសាស្ត្របានថយចុះពីមួយឆ្នាំទៅមួយឆ្នាំពីព្រោះដោយដោយសារការខ្វះខាតគ្រូបង្រៀន និងសមត្ថភាពនៅមានកំរិត។ គ្រូបង្រៀនវិទ្យាសាស្ត្រមិនត្រឹមតែត្រូវចេះចាំនូវទ្រឹស្តីប៉ុណ្ណោះទេ តែគ្រូបង្រៀនតំរូវអោយមានជំនាញ និងបទពិសោធន៍ក្នុងការប្រើប្រាស់មន្ទីពិសោធន៍ផងដែរ។

យោងតាមកិច្ចសំភាសន៍ជនគន្លិះជាមួយនាយកសាលានានាបានបង្ហាញថា គណៈគ្រប់គ្រងសាលាមានការគ្រាំទ្រខ្លាំងក្នុងការលើកទឹកចិត្តដល់គ្រូបង្រៀនដើម្បីបន្តការសិក្សា ជាពិសេសអ្នកដែលមិនទាន់មានបរិញ្ញាប័ត្រ។ ទោះបីជាសាលាពុំមាន ថវិការសំរាប់ផ្តល់ជូនគ្រូបង្រៀនក្នុងការបន្តការសិក្សាក៏ដោយ តែសាលាបានបង្កបរិយាកាសអំណោយផលក្នុងការអនុញ្ញាត្តអោយបន្តការសិក្សាសាលាឯកជន ឬការផ្តល់អាហារូបករណ៍តាមរយៈក្រសួងអប់រំយុវជននិងកីឡា។ បើយោងទៅតាម លោកអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ មន្ទីរបានធ្វើការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងអាហារូបករណ៍ដែលទទួលបានក្រសួងអប់រំយុវជននិងកីឡាពីយ៉ាងទូលំទូលាយ តាមរយៈ Page Facebook របស់មន្ទីរ និងតេលេក្រាម។ ជាងនេះមន្ទីរក៏បាន ផ្តល់ឱកាស និងលើកទឹកចិត្តដល់គ្រូ និងនាយកដែលមានបំណងចង់សិក្សា ជាពិសេសសម្រាប់វគ្គគ្រូពន្លឿនពីកម្រិតបឋមភូមិ ទៅទុតិយភូមិ និងបានជួយសម្រួលដល់បេក្ខជនក្នុងរៀបចំឯកសាររដ្ឋបាលផ្សេងៗ។ ដូច្នេះហើយទើបចំនួនអ្នកដែលទទួលបានការអប់រំកំរិតអប់រំបរិញ្ញប័ត្ររបស់អ្នកឆ្លើយតបដែលទទួលបានមានកំរិតខ្ពស់គួរអោយកត់សំគាល់។

**រូបភាពទី២.** មុខវិទ្យាដែលអ្នកឆ្លើយតបរៀនក្រោមគម្រោងUSESDP-ADB



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ដើម្បីលើកកំពស់ការអប់រំSTEM នៅសាលាជនបទ និងតំបន់ដាច់ស្រយាលធានាគារអភិវឌ្ឍន៍អាស៊ី(ADB) បានកំពុងធ្វើការងារ ជាមួយក្រសួងអប់រំយុវជននិងកីឡាតាមរយៈវិទ្យាស្ថានជាតិអប់រំក្នុងការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមរយៈពេលមួយឆ្នាំ។ គំរោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP)មានរយៈពេលបួនឆ្នាំនេះ ហើយបានអនុវត្តន៍ចាប់តាំងពីឆ្នាំ២០១៧ក្នុងការផ្តល់អាហារូបករណ៍សរុបចំនួន៥០០នាក់ លើមុខវិជ្ជាមុខវិទ្យាវិជ្ជាសាស្ត្រនិងភាសានៅក្នុងនោះមានស្ត្រីចំនួន ៤០ ភាគរយ[1]។ រូបភាពទី២ បានបង្ហាញថា ជិតពាក់កណ្តាលអ្នកឆ្លើយតប បានរៀនមុខវិជ្ជារូបវិទ្យា (23.1%) និងគណិតវិទ្យា (20.4%) ហើយ 15.7% រៀនភាសាអង់គ្លេស 13.9%រៀនជីវះវិទ្យា 10.2%គីមីវិទ្យា 9.3%ពត៌មានវិទ្យា និង4.7%ផែនដីវិទ្យា។ បើប្រៀបធៀប គរុនិស្សិតជាស្ត្រីដែលបានសិក្សាលើមុខវិជ្ជារូបវិទ្យា (27.9%) ជីវះវិទ្យា (27.9)% និងផែនដីវិទ្យា(7.0%) មានចំនួនភាគរយច្រើនជាងគរុនិស្សិតជាបុរស។

ក្នុងកិច្ចពិភាក្សាក្រុមក្នុងចំណោមនាយកសាលាខេត្តត្បូងឃ្មុំបានលើកឡើងថាគំរោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP)ក្នុងការជួយពង្រឹងចំណេះដឹង និងជំនាញរបស់គ្រូបង្រៀនលើមុខវិជ្ជាមុខវិទ្យាវិជ្ជាសាស្ត្រ និងភាសានៅសាលាជនបទ និងតំបន់ដាច់ស្រយាលដែលកំពុងខ្វះខាតពីព្រោះសមត្ថភាពរបស់ពួកគាត់នៅមានកំរិតនៅឡើយ។ ក្រុមនាយកសាលាបានទទួលស្គាល់ថាគ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១ ចេញពីវិទ្យាស្ថានជាតិអប់រំ មានការយល់ដឹងទូលំទូលាយ បន្ថែមលើឯកទេស និងចំណេះដឹងទ្រឹស្តីគរុកោសល្យ និងមានភាពច្នៃប្រឌិត។ប៉ុន្តែការទាក់ទាញចំណូលចិត្តសិស្សក្នុងការបង្រៀន នៅមានកម្រិត ដោយបទពិសោធន៍នៅស្ទើរ ដែលត្រូវរៀនបន្ថែមពីគ្រូដែលមានបទពិសោធន៍។ ការយកចិត្តទុកដាក់ក្នុងការបង្រៀនក៏ជាកត្តាមួយយ៉ាងសំខាន់ក្នុងការផ្តល់ចំណេះដឹងដែលមានគុណភាពខ្ពស់ និងមានប្រសិទ្ធភាពផងដែរ។ លោកនាយកសាលា បានទទួលផងដែរថាបើមានតែចំណេះដឹង តែគ្មានការតាំងចិត្ត និងការស្ម័គ្រចិត្តក៏មិនអាចធ្វើអោយគ្រូបង្រៀនអាចបំពេញការងារបានល្អដែរ។

## អាហារូបករណ៍និងការចំណាយប្រចាំខែក្នុងពេលសិក្សា

គរុនិស្សិតគ្រប់រូបដែលកំពុងរៀនគ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១ វិទ្យាស្ថានជាតិគរុកោសស្យបានផ្តល់ប្រាក់ឧបត្ថមចំនួន៨ម៉ឺនរៀលក្នុង១ខែ។ តែដើម្បីទាក់ទាញគរុនិស្សិតក្នុងការជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រ និងភាសា វិទ្យាស្ថានជាតិគរុកោសស្យបានផ្តល់ជាអាហារូបករណ៍ បន្ថែមលើចំនួន32ម៉ឺនរៀលក្នុង១ខែពីធានាគារអភិវឌ្ឍន៍អាស៊ី (ADB) លើអាហារូបករណ៍8ម៉ឺនរៀលពីវិទ្យាស្ថាន (រូបភាពទី៣)។ ប៉ុន្តែ

[1] USESDP-181125_NIE_scholarship follow-up

*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ដើម្បីទទួលបានអាហារូបករណ៍ គរុនិស្សិតត្រូវបំពេញតាមលក្ខខណ្ឌកំណត់របស់វិទ្យាស្ថានជាតិអប់រំ និងកិច្ចសន្យារបស់ គម្រោង USESDP-ADB។ គរុនិស្សិតដែលទទួលអាហារូបករណ៍ក្រោមគម្រោង USESDP-ADB នឹងរំពឹងថានឹងទៅបំរើការងារនៅខេត្តខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ព្រះវិហារ បន្ទាយមានជ័យ ត្បូងឃ្មុំ ក្រចេះឧត្តមានជ័យ និងកោះកុង។

សំរាប់គរុនិស្សិតដែលសិក្សាក្រោមគម្រោងUSESDP-ADB បាតទទួប្រាក់ឧបត្ថមបន្ថែម ចំនួន40ម៉ឺនរៀលក្នុង១ខែ។ កាមការវិភាគក្នុងរូបភាពទី៣បានបង្ហាញថាប្រាក់ឧបត្ថមនេះ (40ម៉ឺនរៀលក្នុង១ខែ) វានៅតិចជាងការចំណាយប្រចាំខែជាក់ស្តែងខ្លាំងណាស់(94ម៉ឺនរៀលក្នុង១ខែ) ។ជាមធ្យម អ្នកឆ្លើយតបក្នុងពេលរៀនគ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១ បានចំណាយលើ អាហារ (368,056រៀល) ការស្នាក់នៅ (251,713រៀល) ការដឹកជញ្ជូន (88,981រៀល)និងឯកសារ (65,694រៀល) (P-*value* =0.000) ។ យោងតាម T-test បានបង្ហាញឃើញថា ប្រាក់ឧបត្ថមនេះ បានត្រឹមតែជួយសំរួល ឬកាត់បន្ថយការចំណាយរបស់អ្នកឆ្លើយតបគ្រប់ល្មមសម្រាប់តែអាហារ (36ម៉ឺនរៀល) ឬក៏ការស្នាក់នៅ(25ម៉ឺនរៀល) (P-value=0.0000)។ តាមរយៈក្រុមពិភាក្សាក្នុងចំនោមនាយកសាលាក្នុងខេត្តដែលធ្វើការអង្កេតបានបង្ហាញថាការរៀននិងការអភិវឌ្ឍវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់ដែលជួយអោយមានសមិទ្ធិផលការសិក្សារបស់សិស្ស។ ការរៀនសូត្រឬបណ្តុះបណ្តាលគ្រូគឺជាដំណើរការជាបន្តបន្ទាប់ និងការវិនិយោគទន់រយៈពេលវែងឆ្ងាយ ដែលលើកកម្ពស់ជំនាញបង្រៀនរបស់គ្រូក្នុងការបង្កើនចំណេះដឹងថ្មីៗ អភិវឌ្ឍ ជំនាញថ្មីដែលជាហេតុជួយកែលម្អការរៀនសូត្ររបស់សិស្ស។

**រូបភាពទី៣.** ចំនួនសាច់ប្រាក់អាហារូបករណ៍និងការចំណាយប្រចាំខែ



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ក្នុងពេលសំភាសន៍គរុនិស្សិតបានលើកឡើងថា ពួកគាត់មានប្រភពចំណាយសំរាប់ការចាយវាយក្នុងពេលសិក្សាផ្សេងគ្នា តែប្រភពដែលសំខាន់ចេញពីឪពុក ម្តាយ និងការស្វែងរកការងារក្រៅម៉ោងបន្ទាប់ពីការសិក្សា។ពេលសិក្សា គរុនិស្សិតមានឪកាសជាច្រើនក្នុងការរកប្រាក់ចំណូលបន្ថែមដើម្បីយកមកប្រើប្រាស់លើការចំណាយផ្សេងៗ។ តែការធ្វើការងារ ក៏វាប៉ះពាល់ដល់ការសិក្សារបស់ពួកគេដែរជាពិសេសការងារដែលមិនពាក់ព័ន្ធនឹងការបង្រៀន។ មានគរុនិស្សិតមួយចំនួនបានផ្តោតលើតែការសិក្សាដោយប្រើបស្រាស់ការចំណាយបានមកពីឪពុក ម្តាយ និងប្រាក់សន្សំ។ ហើយក៏មានគរុនិស្សិតមួយចំនួនក៏បានធ្វើការងារក្រៅម៉ោង ជាគ្រូបង្រៀនសាលាឯកជន ឬក៏ការបង្រៀនតាមផ្ទះ។ ការគ្រូបង្រៀនសាលាឯកជន ឬក៏ការបង្រៀនតាមផ្ទះក៏បានផ្តល់ជាបទពិសោធន៍ដល់ពួកគាត់នៅពេលដែលពួកគាត់ទៅបង្រៀននៅខេត្តគោលដៅ។

## ការទទួលបានចំណេះដឹង ជំនាញ និងភាពស្ទាត់ជំនាញលើការងារ

រូបភាពីទី៤ ទី៥ និងទី៦ វាយតំលៃលើភាពពេញចិត្តលើការទទួលបាននូវ ដឹង ជំនាញ និងភាពស្ទាត់ជំនាញលើការងារដែលទទួលបានពីវិទ្យាស្ថានជាតិអប់រំ។ជាទូទៅ ភាពស្ទាត់ជំនាញលើការងារ (competency)មានន័យថាជាសមត្ថភាពក្នុងការប្រើប្រាស់ ចំណេះ(knowledge)ដឹង និងជំនាញ (skill) ក្នុងការបំរើការងារក្រោមក្របខ័ណ្ឌការអភិវឌ្ឍន៍វិជ្ជាជីវៈនិងផ្ទាល់ខ្លួន។ នៅក្នុងបរិបទនៃក្របខ័ណ្ឌគុណវុឌ្ឍិសមត្ថភាព ការកសាងសមត្ថភាពរបស់គរុនិស្សិតអោយមាន ទំនួលខុសត្រូវនិងស្វ័យភាពគឺមានសារៈសំខាន់។រូបភាពទី៤. វិភាគពីភាពពេញចិត្តលើការទទួលបានដឹង គរុនិស្សិតទទួលបានចំណេះដឹងខ្ពស់សឹងតែគ្រប់សូចនាករណ៍លើកលែងតែ សីលធម៌បង្រៀនពូកគាត់ទទួលបានខ្ពស់ណាស់។

រូបភាពទី៤. ភាពពេញចិត្តលើចំណេះដឹងពីវិទ្យាស្ថានជាតិអប់រំ



*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ជារួមគរុនិស្សិតទទួលបានការពេញចិត្តខ្ពស់ក្នុងការទទួលបានចំណេះដឹងខ្ពស់ពីវិទ្យាស្ថានជាតិអប់រំ។ក្នុងចំណោមសូចនាករណ៍ទាំង៩ដែលប្រើប្រាស់ក្នុងការវាស់ពីចំណេះដឹងដែលទទួលបាន មានតែសូចនាករណ៍ "សីលធម៌បង្រៀន" ទេ ដែលគរុនិស្សិតវាយតំលៃថាបាទទទួលចំណេះដឹងបានខ្ពស់ណាស់។ តាមជាក់ស្តែង គ្រូបង្រៀនដែលបានឆ្លងកាត់វិទ្យាស្ថានជាតិអប់រំ និងមិនបានមានលក្ខណះខុសគ្នា ជាទូទៅគ្រូបង្រៀនដែលបានឆ្លងកាត់វិទ្យាស្ថានជាតិអប់រំមានសីលធម៌បង្រៀនខ្ពស់ជាង។ការទទួលបានចំណេះដឹង និង ការយល់ដឹងអំពីទ្រឹស្តី និងការអនុវត្តន៍នៃការរៀនសូត្រជួយគ្រូឱ្យផ្សារភ្ជាប់សិស្សគ្រប់ប្រភេទ។ គ្រូអាចផ្តោតលើស្ទីលរៀនខុសៗគ្នាដើម្បីឈានទៅដល់សិស្សផ្សេងៗបង្កើតការបង្រៀនដែលផ្តោតដោយផ្ទាល់ទៅលើតម្រូវការរបស់សិស្សនិងអាកប្បកិរិយា។ នៅវិទ្យាស្ថានជាតិអប់រំ គរុនិស្សិតមានឱកាសក្នុងការទទួលបានទាំងទ្រឹស្តី និងការអនុវត្តដើម្បីបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអោយមានគុណភាពខ្ពស់។ បទពិសោធន៍និងការអង្កេត ពីនាយកសាលានៅខេត្តក្រចេះបានបង្ហាញថា គ្រូដែលបានបញ្ចប់វគ្គគរុកោសល្យមានសមត្ថភាពកើនល្អគួរកត់សម្គាល់ផ្នែកចំណេះដឹងលើមុខវិជ្ជាឯកទេស និងវិធីសាស្ត្របង្រៀនថ្មីៗ។ ជាពិសេសការបង្រៀនមានភាពទន់ភ្លន់ និងទាក់ទាញចំណាប់អារម្មណ៍សិស្សជាងមុន។

គ្រូបង្រៀនត្រូវការជំនាញការអប់រំនិងបណ្តុះបណ្តាលផ្សេងៗគ្នាដើម្បីក្លាយជាអ្នកជំនាញក្នុងអាជីព។ ក្នុងការវយតំលៃភាពពេញចិត្ត អ្នកឆ្លើយតបបានវាយតំលៃខ្ពស់លើសូចនាករណ៍៦ ក្នុងចំណោម៧ ក្នុងរូបភាពទី៥ តែអ្នកឆ្លើយតបបានវាយតំលៃត្រឹមតែមធ្យមលើការផលិតឧបករណ៍ពិសោធន៍។ ជារួមសមត្ថភាពគ្រូបង្រៀនក្នុងការផលិតឧបករណ៍ពិសោធន៍នៅមានកំរិតហើយក៏កត្តាដែលរាំងស្ទះលើគុណភាពបង្រៀនផ្នែកវិទ្យាសាស្ត្រផងដែរ។ក្នុងកិច្ចសំភាសន៍ លោកនាយកសាលានៅខេត្តក្រចេះបានមានប្រសាសន៍ថា" ជាងនេះទៅទៀត ពួកគាត់ [គរុនិស្សិតដែលបានបញ្ចប់គ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១] យល់ដឹងច្រើនផ្នែកទ្រឹស្តី ប៉ុន្តែសមត្ថភាពពិសោធន៍ ហាក់មិនសូវមានការ ប្រែប្រួលខុសពីមុនប៉ុន្មាន។ កិច្ចសហការ និងស្មារតីទទួលខុសត្រូវលើការបំពេញការងារល្អជាងមុន មានចំណេះដឹងបន្ថែមកុំព្យូទ័រ អាចប្រើប្រាស់បានខ្លះៗ។ប៉ុន្តែជំនាញសហការជួយឱ្យពួកគេធ្វើការប្រកបដោយផលិតភាពជាមួយមិត្តរួមការងារ" ។

រូបភាពទី ៥. ភាពពេញចិត្តលើជំនាញពីវិទ្យាស្ថានជាតិអប់រំ



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

នៅខេត្តត្បូងឃ្មុំ នាយកសាលានាយកសាលាបាន គោតសរសើរគ្រូដែលបានបញ្ចប់កម្រិតឧត្តមបរិញ្ញាបត្រ+១ ដែលពួកគាត់មាន មានចំណេះដឹងទូលំទូលាយ និងសមត្ថភាពខ្ពស់លើមុខវិជ្ជាឯកទេស និងគរុកោសល្យ ឬវិធីសាស្ត្របង្រៀន (ទ្រឹស្តី)។ប៉ុន្តែការបង្រៀនជាក់ស្តែង និងគ្រប់គ្រងថ្នាក់រៀននៅមិនទាន់បានល្អ (ខ្វះបទពិសោធន៍) ហើយបំណិនពិសោធន៍ជាក់ស្តែង (មុខវិជ្ជាពិសោធន៍) នៅមានកម្រិត។ គ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១ ចេញពីវិទ្យាស្ថានជាតិអប់រំ ភាគច្រើនមានស្មារតីទទួលខុសត្រូវលើ ការងារខ្ពស់ មានភាពរហ័សរហួន និងចេះច្នៃប្រឌិត ដែលអាចដោះស្រាយបញ្ហាបានច្រើន ដូចជា ក្នុងអំឡុងកូវីដ១៩ ជួយកាត់ត ឬរៀបចំមេរៀនបង្រៀនអនឡាញជាដើម។ វាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនវិទ្យាសាស្ត្រត្រូវមានចំណេះដឹង និងជំនាញតាមទាន់បដិបទប្រទេស តំបនង់និងពិភពលោក។ជាក់ស្តែងក្នុងជំឡុងពេលកូវិដ គ្រូដែលបានបញ្ចប់កម្រិតឧត្តមបរិញ្ញាបត្រ+១ ក៏បានជួយបង្រៀនដល់គ្រូផ្សេងៗក្នុសាលាក្នុងការបង្រៀនដោយប្រើស្មាតហ្វូន អាយផេត និងកុំព្យូទ័ត។

រូបភាពទី ៦. ភាពពេញចិត្តលើភាពស្ទាត់ជំនាញលើការងារពីវិទ្យាស្ថានជាតិអប់រំ



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

រូបភាពទី ៦. វាយតំលៃភាពពេញចិត្តលើភាពស្ទាត់ជំនាញលើការងារដែលទទួលបានដោយគរុនិស្សិតពីវិទ្យាស្ថានជាតិអប់រំ។ ភាពស្ទាត់ជំនាញលើការងារគឺជាសមត្ថកិច្ចដែលទាក់ទងនឹងសមត្ថភាពក្នុងប្រើប្រាស់ជំនាញ និងចំណេះដឹង។នៅសាលារៀន ភាពស្ទាត់ជំនាញលើការងាររបស់គ្រូគឺជាសមត្ថភាពក្នុងការគ្រប់គ្រងការគ្រប់គ្រងការបង្រៀនដែលរួមទាំងការធ្វើផែនការ ការអនុវត្ត និងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស។ ជាសេចក្តីរំពឹងពីការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ គឺដើម្បីបង្កើនចំណេះដឹងជំនាញ និងភាពស្ទាត់ជំនាញលើការងារដល់គរុនិស្សិតដើម្បីទៅបំរើការនៅតាមវិទ្យាល័យជាពិសេសនៅទីជនបទ និងតំបន់ដាច់ស្រយាលដែលកំពុងប្រឈមក្នុងការខ្វះគ្រូបង្រៀនផ្នែកវិទ្យាសាស្រ្ត និងភាសា។ ក្នុងការវាយតំលៃលើភាពស្ទាត់ជំនាញលើការងារ អ្នកឆ្លើយតបបានវាយតំលៃខ្ពស់លើសូចនាករណ៍ទាំង៩។ ការពង្រឹងភាពស្ទាត់ជំនាញលើការងារនៅពេលរៀននៅវិទ្យាស្ថានជាតិអប់រំ វាមានសារៈសំខាន់ពីព្រោះភាពស្ទាត់ជំនាញលើការងាររួមបញ្ចូលទាំងជំនាញនិងចំណេះដឹងដែលអាចជួយឱ្យគ្រូទទួលបានជោគជ័យ។ ដើម្បីបង្កើនគុណភាពសិក្សារបស់សិស្ស គ្រូបង្រៀនក៍ត្រូវការមាន ជំនាញនៅក្នុងជួរដ៏ទូលំទូលាយនៅក្នុងបរិយាកាសស្មុគស្មាញជាពិសេសដែលការសម្រេចចិត្តសំខាន់ៗ។

គ្រូបង្រៀនក៏ត្រូវការជំនាញអន្តរបុគ្គល( Interpersonal Skil )ផងដែរដូចជាការអត់ធ្មត់និងសមត្ថភាពក្នុងការរក្សាភាពស្ងប់ស្ងាត់ក្នុងស្ថានភាពស្រ្តេស។ប៉ុន្តែ នាយកសាលាហាក់ដូចមិនសូវពេញចិត្តទៅនឹងភាពអំណួតរបស់គ្រូបង្រៀនដែលបានបញ្ចប់កម្រិតឧត្តមបរិញ្ញាបត្រ+១។ តាមកិច្ចពិភាក្សាក្រុម លោកនាយកសាលានៅខេត្តត្បូងឃ្មុំបានលើកឡើងថា ″ទោះជាយ៉ាងនេះក្តី គ្រូកម្រិតឧត្តមនេះ នៅមានកម្រិតសមត្ថភាពផ្នែកទំនាក់ទំនងអន្តរបុគ្គល( Interpersonal Skil ) ហើយអ្នកខ្លះមានអំណួតនឹងកម្រិតសញ្ញាបត្រ និងកិច្ចការបង្រៀនមួយចំនួនធ្វើមិនសូវបានល្អ ដែលនេះតម្រូវឱ្យពួកគាត់រៀនសូត្របន្ថែមពីគ្រូចាស់ៗ។″

## ភាពពេញចិត្តចំពោះកម្មវិធីសិក្សា

យោងតាមកិច្ចពិភាក្សាជាមួយស្ថប័នពាក់ព័ន្ធនានា កម្មវិធីសិក្សា(curriculum)ល្អមានមុខងារជាឯកសារយោងនិងជាអគមគុទេសនាំផ្លូវគ្រូក្នុងការបង្រៀន។ កម្មវិធីសិក្សា( curriculum )ក៏ជាអ្នកកំណត់ពីលទ្ធផលនៃការរៀន និងបង្រៀន និងសមត្ថភាពស្នូលដែលសិស្សត្រូវតែបង្ហាញមុនពេលឈានដល់កម្រិតបន្ទាប់។ បើយោងទៅតាមគ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ ការបណ្តុះបណ្តាល គ្រូឧទ្ទេសអនុវត្តតាមកម្មវិធីសិក្សាដែលមានស្រាប់ និងងការរៀបចំកម្មវិធីសិក្សាធ្វើឡើងដោយមានការពិភាក្សាជាមួយគ្រូតាម មុខវិជ្ជារៀងៗខ្លួន។លោកគ្រូគ្រូឧទ្ទេសក៏បានបង្ហាញពីភាពខុសគ្នារបស់គរុនិស្សិត មុនពេលចូលរៀន ពួកគាត់ពុំមានបទពិសោធន៍ទាល់តែសោះ ខ្វះបច្ចេកទេស ពុំមានសមត្ថភាពគ្រប់គ្រាន់ និងមិនមានភាពបត់បែននិងទំនុកចិត្តក្នុង ការបង្រៀន។ ប៉ុន្តែបន្ទាប់ពីបញ្ចប់ការសិក្សាពីវិទ្យស្ថានជាតិគរុកោសស្ស គរុនិស្សិតត្រូវ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

បាន ឆ្លងកាត់ការវាយតម្លៃឃើញថា មានទំនុកចិត្តក្នុង ការបង្រៀន មានសមត្ថភាព លើមុខវិជ្ជាឯកទេសសម្រាប់ការបង្រៀនច្រើនជាងមុន។ នេះបញ្ជាក់ពីប្រសិទ្ធភាពនៃកម្មវិធីសិក្សា(curriculum)។

ក្នុងពេលជាមួយគ្នានេះដែរអ្នកឆ្លើយតបបានបង្ហាញការពេញចិត្តខ្ពស់លើកម្មវិធីសិក្សា លើកលែងតែ សូចករទាក់ទងនឹងឱកាសហាត់ការ ពួកគាត់ពេញចិត្តត្រឹមតែមធ្យមប៉ុណ្ណោះ។ ក្នុងជំឡុងពេលធ្វើការអង្កេត គរុនិស្សិតបានបង្ហាញពីសារៈសំខាន់នៃឱកាសហាត់ការ ហើយពួកគាត់ស្នើសុំអោយមានការបង្កើនឳកាសដល់គរុនិស្សិតជាពិសេសអោយបានមានពេលបង្រៀនផ្ទាល់ក្នុងថ្នាក់អោយបានច្រើន ក៏ដូចជាមានឳកាស់ក្នុងការបំរើការនៅការិយាល័យនៅតាមសាលារដ្ឋឯកជន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិអង្គការសហប្រជាជាតិ ដើម្បីទទួលចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងការគ្រប់គ្រង និងការងាររដ្ឋបាលក្នុងវិស័យអប់រំ។ ឱកាសហាត់ការបានផ្តល់នូវបទពិសោធន៍ការងារដែលជួយឱ្យគរុនិស្សិតបានអនុវត្តនូវអ្វីដែលបានរៀន ដែលជួយអោយ ពួកគេអាចអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំនិងផ្តល់ឱ្យពួកគេនូវគុណសម្បត្តិប្រកួតប្រជែងនៅពេលពួកគេទៅបងៀននៅតាមវិទ្យាល័យនៅតំបន់ដាច់ស្រយាល និងជនបទ។

**តារាងទី១**.ភាពពេញចិត្តចំពោះកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ

| Attribute | Male | | Female | | Overall | | P-value |
|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | |
| Content | 0.75 | H | 0.76 | H | 0.75 | H | 0.745 |
| Methods | 0.77 | H | 0.78 | H | 0.77 | H | 0.843 |
| Sufficient time | 0.73 | H | 0.72 | H | 0.72 | H | 0.852 |
| Presence of lecturer | 0.67 | H | 0.71 | H | 0.69 | H | 0.245 |
| Assignment | 0.75 | H | 0.80 | H | 0.77 | H | 0.067 |
| Teaching materials | 0.67 | H | 0.70 | H | 0.68 | H | 0.310 |
| Sufficient book | 0.70 | H | 0.72 | H | 0.71 | H | 0.717 |
| Research materials | 0.70 | H | 0.67 | H | 0.69 | H | 0.301 |
| Research opportunity | 0.72 | H | 0.77 | H | 0.74 | H | 0.172 |
| Opportunity to apply | 0.65 | H | 0.73 | H | 0.69 | H | **0.016**** |
| Field visit | 0.75 | H | 0.72 | H | 0.74 | H | 0.424 |
| Thesis supervision | 0.65 | H | 0.70 | H | 0.67 | H | 0.111 |
| Internship | 0.60 | M | 0.56 | M | 0.59 | M | 0.337 |

ការវិភាគ t-test ក៏បានបង្ហាញថាទស្សនៈអ្នកឆ្លើយតបជាស្ត្រីពេញចិត្តខ្លាំងជាងអ្នកឆ្លើយជាបុរសលើឱកាសដែលបានអនុវត្តលើទ្រឹស្តី (P-value=0.003)។ បើយោងទៅតាម នាយកវិទ្យាស្ថានជាតិគរុកោសល្យ វិទ្យស្ថានជាតិគរុកោសល្យជាស្ថាប័នដែលបានបណ្តុះបណ្តាលគ្រូបង្រៀនធំជាងគេ ដែលបានកំពុងផលិតគ្រូបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ផ្គត់ផ្គង់គ្រូបង្រៀនក្នុងប្រទេសកម្ពុជា។ក្នុងមួយឆ្នាំវិទ្យស្ថានជាតិគរុកោសល្យ ផលិតគ្រូបង្រៀនបានប្រហែល១០០០ នាក់ហើយពួកគាត់ត្រូវបានបញ្ជូនទៅធ្វើការទូទាំងប្រទេស។ ពិសេសស គរុនិស្សិតដែលសិក្សាក្រោមគម្រោងUSESDP-ADBត្រូវបញ្ជូនទៅបង្រៀនតំបន់ដាច់ស្រយាលទាំង៧។ យោងតាមគ្រូឧទេស គរុនិស្សិតទាំងអស់មានឳកាសស្មើគ្នាក្នុងការ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

អនុវត្តក្នុងមន្ទីរពិសោធន៍ក្តី ក្នុងថ្នាក់រៀនក្តី តែភាពខុសគ្នាគឺមកពីការតាំងចិត្ត ការយកចិត្តទុក្ខដាក់ និងការព្យាយាមរបស់គរុនិស្សិតទេ។ ប្រសិនបើគរុនិស្សិតណាដែលបានចំណាយពេលលើការអនុវត្តន៍បានកាន់តែច្រើន នោះនឹងទទួលបានបទពិសោធន៍ ក៏ដូចជាស្នាត់ជំនាញលើការងារ(competency) កាន់តែច្រើន។

Regression ត្រូវបានប្រើប្រាស់ដើម្បីព្យាករណ៍ពីកក្តាដែលធ្វើឱ្យចំណេះ(skill) កើនរួមមានខ្លឹមសារបង្រៀន(content) វិធីសាស្រ្តបង្រៀន (method) និងការតម្រង់ទិសនិងការជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវ (research supervision) ។ លោកប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្តស្ទឹងត្រែងបានយល់ស្របលើសារៈសំខាន់ពីការងារស្រាវជ្រាវរបស់គ្រូបង្រៀនពីព្រោះវាជួយអោយសមត្ថភាពគ្រូបង្រៀនប្រសើរជាងមុន ហើយគ្រូបង្រៀនក៏មានចំណេះដឹងថ្មីៗក្នុងការបង្រៀនដល់សិស្ស។ គរុនិស្សិតក៏មានទស្សនៈស្រដៀងដែរ ហើយបានបង្ហាញពីភាពសំបូរបែប និងភាពងាយស្រួលក្នុការទទួលបានចំណេះដឹង និងបទពិសោធន៍ក្នុងការធ្វើពិសោធន៍នានា។ គ្រូបង្រៀនអាចទទួលបានការពន្យល់ និងបង្រៀនពីរបៀបសោធន៍ដោយឥតគិតថ្លៃពីប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា YouTube និងFacebook Page. នៅក្នុងវេទការអប់រំ លើកទី២ ស្តីពី″ការពិភាក្សាទៅលើការអប់រំ STEM នៅពេលបច្ចុប្បន្ន និងផែនការនៅឆ្នាំ២០៣០″ នៅថ្ងៃទី២០ តុលា ២០២០ អង្គការSTEM Sisters Cambodiaបានបង្កើត Facebook page ដែលមានវីដែអូជាភាសាខ្មែរដែលបង្រៀនពីរបៀធ្វើពិសោធន៍ ក៏ដូចជាការស្វែងរកឧបករណ៍ងាយដែលមាននៅក្នុងសាលាក្នុងការធ្វើពិសោធន៍ដល់សិស្សក្នុងការអនុវត្តជាក់ស្តែង។ ប៉ុន្តែគរុនិស្សិតក៏បានលើកឡើងដែរថាវិដេអូដែលមានជាភាសារខ្មែរនៅមានកំរិតទាប ពួកគាត់មានឧបសគ្គក្នុងការស្តាប់ ឬយល់ឯកការ និងវិដេអូជាភាសាអង់គ្លេសដែលមានបទពិសោធន៍ល្អៗ។

**តារាងទី២**.កក្តាដែលធ្វើឱ្យចំណេះដឹងកើន

| Attribute | Unstandardized Coefficients | | Standardized Coefficients | P-value |
|---|---|---|---|---|
| | B | Std. Error | Beta | |
| (Constant) | 0.192 | 0.071 | | 0.008 |
| Content | 0.168 | 0.070 | 0.223 | 0.019** |
| Methods | 0.181 | 0.071 | 0.237 | 0.013** |
| Sufficient time | 0.053 | 0.054 | 0.086 | 0.334 |
| Presence of lecturer | 0.056 | 0.053 | 0.108 | 0.295 |
| Assignment | 0.051 | 0.058 | 0.079 | 0.379 |
| Sufficient teaching materials | 0.030 | 0.059 | 0.051 | 0.613 |
| Sufficient book | -0.025 | 0.064 | -0.046 | 0.701 |
| Sufficient research materials | 0.066 | 0.069 | 0.119 | 0.341 |
| Opportunity to do research | -0.036 | 0.050 | -0.069 | 0.474 |
| Opportunity to apply | 0.005 | 0.048 | 0.011 | 0.912 |

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

| | | | | |
|---|---|---|---|---|
| Field visit | 0.006 | 0.039 | 0.013 | 0.884 |
| Thesis supervision | 0.146 | 0.048 | 0.278 | 0.003** |
| Internship | 0.047 | 0.037 | 0.116 | 0.202 |

ខ្លឹមសារបង្រៀន(content) និងវិធីសាស្ត្របង្រៀន (method)របស់គ្រូឧទេសនៅវិទ្យាស្ថានជាតិគរុកោសល្យមានសារៈសំខាន់ក្នុងការបង្កើនចំណេះដឹងរបស់គរុនិស្សិត។យោងតាមអ្នកជំនាញអប់រំបានបង្ហាញថា ចំណេះដឹងរបស់គរុនិស្សិត វាអស្រ័យលើគុណភាពដែលផ្តល់ពីការបណ្តុះបណ្តាលគរុកោសល្យល្អ ដែលបានផ្តល់នូវ សារបង្រៀន(content) ចំណេះដឹង គរុកោសល្យ និងជំនាញគ្រប់គ្រងថ្នាក់ (រួមទាំងការអនុវត្តបង្រៀន) ដោយបានត្រឹមត្រូវតាមមាត្រដ្ឋានខ្ពស់។ជាងនេះទៅទៀត វិធីសាស្ត្របង្រៀន (method)របស់គ្រូឧទេសមានសារៈសំខាន់ក្នុងការទាក់ទាញក៏ដូចជាប្រសិទ្ធភាពក្នុងការផ្ទេតចំណេះដឹងដល់គរុនិស្សិត។ គរុនិស្សិតបានលើឡើងថា មានវិធីជាច្រើនដែលសិស្សដែលអាចរៀនអ្វីមួយបានយ៉ាងលឿន តែវិធីសាស្ត្របង្រៀន(method) មានប្រសិទ្ធភាពជាងគេក្នុងចំណោមវិធីផ្សេងទៀត។ ជាងនេះទៅទៀត វិធីសាស្ត្របង្រៀន (method) មានឥទ្ធិពលដល់ការរៀនសូត្រនិងការលើកទឹកចិត្ត។

ទាក់ទងនឹងភាពស្ទាត់ជំនាញការងារសព្ទ (competency) ការវិភាគRegression បានបង្ហាញថាកត្តាដែលធ្វើឱ្យចំណេះដឹងកើនរួមមាន សមត្ថភាពយល់ដឹង (Cognitive capacity) និង ការចូលរួមការងារសង្គម(social capacity)។ យោងតាម មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ លោកអនុប្រធានបាន បានសង្កេតឃើញថាសមត្ថភាពរបស់គរុនិស្សិតបានកើនឡើង ដោយសារមន្ទីរតែងតែតាមដានជាប្រចាំអំពីការបង្រៀនរបស់ពួកគាត់ ជាមួយនឹងលទ្ធផលនៃការវាយតម្លៃរបស់សាលាដែលបញ្ជូនមក។ ក្នុងនោះលោកបានបញ្ជាក់ថា គរុនិស្សិតដែលបានចេញមកបម្រើការងារនៅតាមសាលាទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស ដោយសារពួកគេមានការយល់ដឹងខ្ពស់ទាំងទៅលើផ្នែកទ្រឹស្តី ការពិសោធន៍ ភាសា និងកុំព្យូទ័រ ក៏ដូចគរុកោសល្យក្នុងការបង្រៀន ដែលធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្សមានការកើនឡើងគួរឱ្យកត់សម្គាល់។ ជាងនេះទៅទៀតគរុនិស្សិតមានសមត្ថភាពអាចរៀបចំ Slide Presentation បានល្អប្រសើរ អាចរៀបចំធ្វើការពិសោធន៍បានល្អ សម្រាប់សាលាដែលមានទីកន្លែងនិងឧបករណ៍គ្រប់គ្រាន់។

ដើម្បីទទួលបានភាពភាពស្ទាត់ជំនាញការងារ (competency) ការចូលរួមការងារសង្គម(social capacity)គ្រូបង្រៀនក៏មានសារៈសំខាបព្ទន់ណាស់។ តួនាទីរបស់គ្រូបង្រៀនមិនត្រឹមតែការបង្រៀនសិស្សក្នុងថ្នាក់នោះទេ តែត្រូវធ្វើការងារយ៉ាងជិតជិតជាមួយអាណាព្យាបាលក្នុងការតាមដានការសិក្សារបស់សិស្ស ក៏ដូចជាការចូលរួមចំណែករបស់ឪពុកម្តាយក្នុងការជួយជ្រុំជ្រែងសិក្សារបស់កូនពួកគាត់។ ជាងនេះទៀតគ្រូបង្រៀនមានតួនាទីសំខាន់ក្នុងការទាក់ទងជាមួយសហគមន៍ និងអញ្ញាធដែនដីក្នុងការ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំ។ ជាងនេះទៅទៀត ការចូលរួម ឬការស្ម័គ្រចិត្តក្នុងការរៀបចំវិធី ឬកម្មវិធីផ្សេងៗក្នុងសាលារិតតែសំខាន់។ ការរៀបចំព្រឹត្តិការណ៍ផ្សេងៗក្នុងសាលាមានសារៈសំខាន់ដើម្បីលើកកំពស់ការយល់ដឹង និងការចូលរួមរបស់សិស្សដើម្បីអភិវឌ្ឍន៍សាលា។ ជាបទពិសោធន៍ នាយកសាលាក្នុងខេត្តត្បូងឃ្មុំ បានកោតសរសើរពី សមត្ថភាពយល់ដឹង (Cognitive capacity) និងការចូលរួមការងារសង្គម (social capacity)របស់គរុនិស្សតដែលបានបញ្ចប់ការសិក្សាកម្រិតឧត្តមបរិញ្ញាបត្រ+១ ពីវិទ្យាស្ថានជាតិអប់រំ។ ក្នុងពេលពិភាក្សាក្រុម លោកនិយកបាននិយាយថា:

> សម្រាប់គ្រូកម្រិតឧត្តមបរិញ្ញាបត្រ+១ ចេញពីវិទ្យាស្ថានជាតិអប់រំ មានការយល់ដឹងទូលំទូលាយ បន្ថែមលើឯកទេស និងចំណេះដឹងទ្រឹស្តីគរុកោសល្យ និងមានភាពច្នៃប្រឌិត។ ពួកគាត់បានចូលរួមសកម្មក្នុងការងារសាលា សហគមន៍ និងសង្គម ជាពិសេសក្នុងអំឡុងកូវីដ បានចុះជួយសិស្សតាមក្រុមតូចៗនៅតាមភូមិយ៉ាងសកម្ម។ បន្ថែមលើនេះ មានស្មារតីទទួលខុសត្រូវខ្ពស់ និងសីលធម៌។

**តារាងទី៣.**កត្តាដែលធ្វើឱ្យភាពស្ទាត់ជំនាញលើការងារកើន

| Attribute | Unstandardized Coefficients | | Standardized Coefficients | P-value |
|---|---|---|---|---|
| | B | Std. Error | Beta | |
| (Constant) | 0.127 | 0.053 | | 0.019 |
| Knowledge obtained | 0.049 | 0.098 | 0.049 | 0.620 |
| Skill obtained | 0.148 | 0.079 | 0.174 | 0.064 |
| Cognitive capacity | 0.285 | 0.078 | 0.327 | 0.000*** |
| Emotional capacity | 0.134 | 0.077 | 0.153 | 0.084 |
| Intellectual capacity | 0.087 | 0.078 | 0.100 | 0.273 |
| Social capacity | 0.124 | 0.061 | 0.174 | 0.047* |

## វិសាលភាពកិច្ចសន្យាអាហារូបករណ៍ក្រោមគម្រោងUSESDP-ADB

ចំពោះគរុនិស្សិតដែលទទួលអាហារូបករណ៍ពីគម្រោងUSESDP-ADB ត្រូវគោរពតាមកិច្ចសន្យាក្នុងការបំពេញការងារតាមខេត្តគោលដៅនៅពេលបញ្ចប់ការសិក្សានៅនៅវិទ្យាស្ថានជាតិអប់រំ។ កិច្ចសន្យាអាហារូបករណ៍ រវាងវិទ្យាស្ថានជាតិអប់រំ និងគរុនិស្សិត មានខ្លឹមសារសំខាន់ដូចជា"សុខចិត្តទទួលយកអាហារូបករណ៍ពីគម្រោងUSESDP ADB-LoanNo3427CAM(SF)និងទៅបម្រើការងារ (*ប៉ុស្តិ៍រាជធានី-ខេត្តដែលត្រូវជ្រើសរើសទៅបម្រើការងារ*)ដោយឥតលក្ខខណ្ឌនៅតាមរាជធានី-ខេត្ត ដែលខ្លួនបានជ្រើសរើសរយៈពេល៥ឆ្នាំ យ៉ាងតិច។ក្នុងករណីដែលផ្ទុយពីប្រការខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំសុខចិត្តទទួលសងប្រាក់អាហារូបករណ៍របស់គម្រោង USESDP ADB-LoanNo3427CAM(SF) ទាំងអស់ គ្រប់ចំនួន។"

យោងទៅតាមរូបភាពទី ៧. 73.1%នៃអ្នកឆ្លើយតប ក្នុងនោះប្រុស76.9 ស្រី67.4 បានឆ្លើយថាកិច្ចសន្យាដែលផ្តល់អោយអាចទទួលយកបាន។បើយោងតាមអ្នកសំរួលគម្រោង USESDP ADB នៅវិទ្យា

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ស្ថានជាតិអប់រំ បានបង្ហាញថាកិច្ចសន្យានេះមានសារៈសំខាន់ហើយគរុនិស្សិតត្រូវតែគោរពអោយបានដាច់ខាត។ បើយោងតាមរបាយការណ៍តាមដាន របស់វិទ្យាស្ថានជាតិអប់រំស្តីពីអ្នកបញ្ចប់ការសិក្សាគម្រោង USESDP ADB បានបង្ហាញថាឆ្នាំទី១នៃគំរោងមានអ្នកទទួលអាហាររូបករណ៍ក្រោមគម្រោងចំនួន៦៧នាក់ក្នុងនេះមានស្រ្តីចំនួន២៨នានក់បានទទួលអាហាររូបករណ៍។ក្នុងចំណោម៦៧នាក់ មាន៥នាក់មិនបាតទៅបង្រៀននៅខត្តគោលដៅតាមកិច្ចសន្យា។ អ្នកសំរួលគម្រោង USESDP ADB នៅវិទ្យាស្ថានជាតិអប់រំបានពន្យល់ថាវិទ្យាស្ថានជាតិអប់រំមានជំហរអោយអ្នកទាំង៥សងអាហារូបករណ៍របស់គម្រោង USESDP ADB-LoanNo3427CAM(SF) ទាំងអស់ គ្រប់ចំនួនតាមកិច្ចសន្យា តែធានាគារអភិវឌ្ឍន៍អាស៊ី(ADB) សំរួលមិនអោយសង។

ឥលូវវិទ្យាស្ថានជាតិអប់រំបានកែខ្លឹមសារកិច្ចសន្យាអាហារូបករណ៍ដោយអោយសងអាហារូបករណ៍របស់គម្រោង USESDP ADB-LoanNo3427CAM(SF)រហួតដល់គុណនឹងពីរ និងប្តេជ្ញាថានឹងអនុវត្តជាដាច់ខាតដើម្បីកុំអោយមានការកេចវេសក្នុងការអនុវត្តកិច្ចសន្យា។ក្នុងរយៈពេល៤ឆ្នាំ វិទ្យាស្ថានជាតិអប់រំមានគម្រោងផ្តល់អាហារូបករណ៍ដល់គរុនិស្សិតរហូតដល់៥០០ នាក់ តែត្រឹមឆ្នាំ២០២០ ដែលជាឆ្នាំទី៣ វិទ្យាស្ថានជាតិអប់រំទើបតែបានផ្តល់អោយដល់គរុនិស្សិតចំនួន២៤៩នាក់ ប៉ុណ្ណោះ។យោយតាមនាយកវិទ្យាស្ថានជាតិអប់រំ មិនបានរើសគរុនិស្សិតថ្មីសម្រាប់ឆ្នាំ២០២១ទេ ដូច្នេះ ការផ្តល់អាហារូបករណ៍គម្រោង USESDP-ADB នឹងផ្ទេរទៅអោយវិទ្យាស្ថានអប់រំផ្សេងដូចជានៅភ្នំពេញ និងបាត់ដំបង។

**រូបភាពទី ៧.** ការទទួលយកបាននូវកិច្ចសន្យា




លក្ខណមុនចូលរៀនគរុនិស្សិតត្រូវចុះកិច្ចសន្យាជាមួនៅវិទ្យាស្ថានជាតិអប់រំ ក្នុងការទទួលបានជានអាហារូបកណ៏ចំនួន320,000រៀលក្នុង១ខែពីគម្រោងUSESDP-ADB។ ដោយតម្រូវឱ្យគរុនិស្សិតទៅ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

បង្រៀននៅខេត្តដែលបានព្រមព្រៀង អ្នកឆ្លើយតប 26.9% បានលើកឡើងថាកិច្ចសន្យានេះមិនអាចទទួលយកបានទេ ដែលក្នុងនេះមានស្ត្រី 32.6% និងបុរស 23.1%។ តាមការវិភាគដោយប្រើ Chi-square បានបង្ហាញឱ្យឃើញថាវាមានទំនាក់ទំនងរវាងការស្នើសុំកែរកុងត្រា និងការមិនអាចទទួលយកបាននូវលក្ខខណ្ឌក្នុងកុងត្រា (P-*value*=0.0000)។

ក្នុងពេលតំភាន់ នាយកសាលាភាគច្រើនហាក់ដូចជាមិនបានដឹងអត្តសញ្ញាណ ថាគរុនិស្សិតនោះបានទទួលអាហារូបករណ៍ក្រោមគម្រោង USESDP ADBឬក៏អត់ទេ ពួកគាត់គ្រាន់តែដឹងថាគ្រូបញ្ជូនមកថ្មីនេះបានរៀនចប់នៅវិទ្យាស្ថានជាតិអប់រំ។ដោយសារវិទ្យាស្ថានជាតិអប់រំជាអ្នករើសគរុនិស្សិតផ្ទាល់ ហើយពេលបញ្ជូនគ្រូបង្រៀនថ្មីក៏មិនបានបញ្ជាក់ថាជាអ្នកបានអាហារូបករណ៍ក្រោមគម្រោងUSESDP-ADB មន្ទីរអប់រំយុវជន និងកីឡាពុំសូវបានស្គាល់ពីគម្រោងUSESDP-ADB នេះដែរ។

ដោយតម្រូវឱ្យគរុនិស្សិតទៅបង្រៀននៅខេត្តដែលបានព្រមព្រៀង អ្នកឆ្លើយតប 26.9% បានលើកឡើងថាកិច្ចសន្យានេះមិនអាចទទួលយកបានទេ ដែលក្នុងនេះមានស្ត្រី 32.6% និងបុរស 23.1%។ តាមការវិភាគដោយប្រើ Chi-square បានបង្ហាញឱ្យឃើញថាវាមានទំនាក់ទំនងរវាងការស្នើសុំកែរកិច្ចសន្យា និងការមិនអាចទទួលយកបាននូវលក្ខខណ្ឌក្នុងកុងត្រា (P-value=0.0000)។ ជារួមសិក្ខាកាមសំណូមពរអោយកែកច្ចសន្យាលើខឹមសារមួយចំនួដូចជា: (1) ចំនួនទឹកប្រាក់អាហារូបករណ៍ដែលផ្តល់អោយមិនសមស្របតាមការចំណាយជាក់ស្តែង (2) បន្ថយរយះពេលបង្រៀននៅសាលាតំបន់ដាច់ស្រយាលយ៉ាងតិច៥ឆ្នាំមកនៅត្រឹមយ៉ាងតិច៣ឆ្នាំវិញ (3) គួរលើកលែងចំពោះករណីលោកគ្រូអ្នកគ្រូដែលទទួលបានអាហារូបករណ៍ទៅរៀនក្រៅប្រទេស (4) គួរតែត្រឹមសង់ប្រាក់សរុបទាំងអស់វិញដោយមិនគុណនិង២ និង(5)គួរផ្តល់ឧបន្ថម្ភបន្ថែមពីគម្រោងចំពោះគ្រូនៅតំបន់ដាច់ស្រយោលអោយស្របតាមជីវភាពជាក់ស្តែង។

**រូបភាពទី ៨.** សំណូមពរក្នុងការកែកិច្ចសន្យា



© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

Chi-square: P-value=0.0000

## ប្រាក់ខែដែលទទួលបាន និងការលើកទឹកចិត្ត

មុនពេលទៅបំរើការតាមខេត្តគោលដៅ គរុនិស្សិតច្រើនជាង50% នៅមិនទាន់មានប្រាក់ខែនៅឡើយទេ ក្នុងនោមានភាគរយគ្រូប្រុស58.5% មានចំនួនទាបជាងគ្រូស្រី 60.5%។ គរុនិស្សិតដែលមិនទាន់មានការងារធ្វើ ពិព្រោះពួកគាត់រៀនបន្តរបន្ទាប់ពីបានបញ្ចប់ពីសាកលវិទ្យាល័យ ហើយពួកគាត់មានគោលដៅច្បាស់ក្នុងការទទួលជាអាជីពជាគ្រូបង្រៀន។ ចំពោះអ្នកដែលមានការងារធ្វើហើយប្រហែលជាអ្នកដែលមានធ្វើការងារក្រៅម៉ោងតាំងពីរៀននៅសាកលវិទ្យាល័យ ឬក៏បានធ្វើការមួយរយៈមុនពេលចូលរៀននៅវិទ្យាស្ថានជាតិអប់រំ។ ការទទួលយកអាជីពជាគ្រូបង្រៀនអាចជាជំរើសមួយដែលគរុនិស្សិតជាច្រើនពីព្រោះវាជាមុខរបរយូរអង្វែង និងស្ថិតស្ថេរ។ ទោះប្បីជា ការងារនៅឯកជនមួយចំនួនអាចផ្តល់ប្រាក់ខែច្រើនជាងអាជីពជាគ្រូបង្រៀន តែគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញាបត្រ+១នៅតែជាជំរើសដ៏ប្រកួតប្រជែងសម្រាប់អ្នកដែលបញ្ចប់បរិញ្ញាប័ត្រ។

**រូបភាពទី ៩.** មានប្រាក់ចំណូលមុនពេលចូលរៀន




អ្នកឆ្លើយតបទទួលបានប្រាក់ខែជាមធ្យម 1.1លានរៀលនៅពេលដែលបំរើការងារជាគ្រូបង្រៀននៅតាមសាលាដែលបញ្ជូនដោយវិទ្យាស្ថានជាតិអប់រំទៅបំរើការតាមខេត្តគោលដៅទាំង៧។ចំពោះអ្នដែលធ្លាប់មានការងារធ្វើមុនមកក្លាយជាគ្រូបង្រៀន ប្រាក់ខែដែលពួកគាត់ទទួលបានរហូតដល់ 1.7លាន

*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

រៀលឯណោះ។ ចំនួននេះច្រើនជាងចំនួនដែលទទួលបាន (P-value=0.0000) មុនពេលចូលបង្រៀន។ ក្នុងពេលធ្វើការអង្កេត គរុនិស្សិតដែលមានការងារ ប្រាក់ខែខ្ពស់រួចហើយបែជាបោះបង់មកធ្វើជាគ្រូបង្រៀន បានចង្អុលបង្ហាញថាធ្វើជាគ្រូបង្រៀនប្រាក់ខែមិនសូវច្រើនដូចការងារឯកជន និងអង្គការពិតមែនតែពួកគេអាចមានពេលច្រើនជាងជាមួយគ្រួសារ ឬអាចប្រកបមុខរបរផ្សេងៗ។ជាងនេះទៅទៀតការងារជាគ្រូនឹងទទួលបានប្រាក់សោតធនិវត្តន៍ ដែលការងារឯកជន និងអង្គការមិនមាន។ ចំពោះប្រាក់បៀវត្តន៍ 1 លានរៀលជាង អាចផ្គត់ផ្គង់ការរស់នៅក្នុងខេត្តគោលដៅទាំ៧បានល្មម ប៉ុន្តែពួកគាត់បាត់តំលៃឱកាស ពីព្រោះតំបន់ដាច់ស្រយាលពុំមានសាលាឯកជនដែលពួកគេអាចទទួលបានប្រាក់ចំណូលបន្ថែមពីការបង្រៀន

បើយោងតាមទិន្នន័យស្រាវជ្រាវរបស់ក្រសួងផែនការ មនុស្សម្នាក់ត្រូវការ4.9សែនរៀលសំរាប់ការផ្គត់ផ្គង់ការចាយវាយប្រចាំខែ(P-value=0.0000)។ ការវិភាគ t-testបានបង្ហាញថាប្រាក់ខែដែលអ្នកឆ្លើយតបទទួលបានមានចំនួនច្រើនជាងដាច់ពីចំនួការផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់មនុស្សម្នាក់ៗ។ ក៏ប៉ុន្តែ ប្រាក់ខែជាគ្រូបង្រៀនតែមួយគត់មិនអាចរាប់រងរាល់ការផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារទាំងមូឡបានទេ(P-value=0.0000)។បើតាមការស្រាវជ្រាវរបស់ក្រសួងផែនការបានកំណត់ថាការផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារ ត្រូវការរហូតដល់ 1.63លានរៀលក្នុង១ខែ។ជាក់ស្តែងក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប្រាក់ខែតែមួយប្រភពមិនអាចផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារទាំងមូលបានទៀតទេ ទោះបីតែការងារនៅឯកជនឬអង្គការក៏ដោយ។ វាមិនខុសប្លែកពីប្រភេទការងារផ្សេងនៅអង្គការក្រៅរដ្ឋាភិបាល ឬឯកជនទេ សមាជិកគ្រួសារត្រូវចេះជួយគ្នាក្នុងការក្នុងការបង្កើតប្រាក់ចំណូលទើមានចំណូលគ្រាប់គ្រាន់ដើម្បីចញ្ចឹមគ្រួសារ។

**រូបភាពទី ១០.** ប្រាក់ខែដែលទទួលបាន



*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

P-*value*=0.0000 ផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារ និងP-value=0.0000 ផ្គត់ផ្គង់ការចាយវាយ ប្រចាំខែផ្ទាល់ខ្លួន

ចំពោះអ្នកឆ្លើយតបប្រាក់ចំណូលដែលបានទទួលពីក្រសួងអប់រំនឹងកីឡា មានចំនួនសមរម្យដើម្បីផ្គត់ផ្គង់ជីវិភាពរស់នៅរបស់ពួកគាត។ ជារួម 77.0% អ្នកឆ្លើយតបនៅលីវ ក្នុងនេះមានគរុនិស្សិតជាបុរស 67.7% និងគរុនិស្សិតជាស្ត្រី76.7%។ក្នុងពេលធ្វើអង្កេត គរុនិស្សិតដែលមានគ្រួសារក៏បង្ហាញពីភាពពេញចិត្តពីប្រាក់បៀវត្តន៍ដែលពួកគេទទួលបាន។ ក្រៅពីបំរើការងារជាអាជីពគ្រូបង្រៀន អ្នកមានគ្រួសារក៏មានពេលវេលាសំរាប់ការប្រកាបមុខរបរផ្សេងទៀតដែរ។ ក្នុងសំនួរមួយដែលសួរថា"តើប្រាក់ខែប៉ុន្មានដែលអ្នករំពឹងបន្ទាប់ពីចូលរៀនបរិញ្ញា+១ក្រោមគម្រោង USESDP ADB"ដែលគរុនិស្សិតអាចបង្រៀនដោយមិនចំណាយពេលធ្វើការងារផ្សេង។ អ្នកឆ្លើយតចង់បានប្រាក់ខែជាមធ្យមរហូតដល់1.6លានរៀលក្នុង១ខែដើម្បីផ្តោតលើការបង្រៀន និងធ្វើកិច្ចការងារសាលាតែមួយគត់។ អ្នកឆ្លើយតបរំពឹងចង់បានប្រាក់បៀវត្តន៍រហូតដល់ 1.6លានរៀលក្នុង១ខែក្នុងពីព្រោះពួកគាត់ចង់បានប្រាក់គ្រប់គ្រាន់សំរាប់ការផ្គត់ផ្គង់គ្រួសារទាំងមូល។ចំនួនដែលទឹកប្រាក់ដែលបានរំពឹង1.6លានរៀល វាជាចំនួនដែលមិនក្រោម ហើយក៏មិនលើសពីការចាយវាយប្រចាំខែរបស់គ្រួសារ (1.63លានរៀល)ដែលបានកំណត់ដោយក្រសួងផែនការ។

យោងតាមរូបភាពទី ១១ អ្នកឆ្លើយតបបានសំណូមពរក្នុងការបង្កើនប្រាក់បៀវត្តន៍ (81.5%) ការបង្កើនប្រាក់ឈ្នួលបង្រៀន(32.4%) ការផ្តល់ផ្ទះស្នាក់ (28.7%) អនុញ្ញាត្តអោយបង្រៀននៅសាលាឯកជន(12.0%) និងផ្តល់ម៉ោងបង្រៀនបន្ថែម(11.1%)។ ជារួមអ្នកឆ្លើយតបជាបុរស មានតំរូវការខ្ពស់ជាង អ្នកឆ្លើយតបជាស្ត្រី។ តាមការសំភាសន៍ អ្នកខឆ្លើយតបបានរៀបរាប់ថា ជីវិតជាគ្រូបង្រៀនទោះប្រាក់ខែមិនច្រើនដូចការងារឯកជន តែមានសិទ្ធិសិរីភាពពេញលេញ។ ជាងនេះទៅទៀតជាការងារដែលត្រូវបានសហគមន៍ និងសង្គមទទួលស្គាល់យ៉ាងទូលំទូលាយ។ដោយសារ គ្រូបង្រៀនដែលមកតាំងលំនៅក្នុងខេត្តដាច់ស្រយាល ការគាំទ្រពិសេស និងបន្ថែមជាភាពទាក់ទាញដោយបំរើការងារយូរអង្វែងដែលអ្នកឆ្លើយតបចង់បានជាការគាំទ្របន្ថែម។

**រូបភាពទី ១១.** ប្រភេទទ្រាំទ្រដែលស្នើសុំ



*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

## អនុសាសន៍សំរាប់អ្នកធ្វើផែនការ និងគោលនយោបាយ

*ក្រសួងអប់រំ យុវជន និងកីឡា*

- ការបន្តផ្តល់អាហាររូបករណ៍ដល់គរុនិស្សិតដែលនឹងទៅបង្រៀននៅខេត្តដាច់ស្រយាលអាចផ្តល់នៅខេត្តនោះផ្ទាល់ ឬក៏ជ្រើសរើសគ្រូបង្រៀននៅកំពុងបង្រៀននៅខេត្តនោះផ្ទាល់ សម្រាប់អ្នកដែលមិនទាន់ទទួលបានការបណ្តុះបណ្តាល។ ការដែរផ្តល់ការបណ្តុះបណ្តាល នៅខត្តនោះផ្ទាល់ ក៏ដូចជាការជ្រើសរើសគ្រូបង្រៀននៅខត្តនោះស្រាប់(មិនទាន់ទទួលបានការបណ្តោះបណ្តាល) អាចជួយអោយកាត់បន្ថយការចំណាយរបស់គរុនិស្សិតក្នុងពេលសិក្សា ក៏ដូចជាអាចទាក់ទាញអោយគរុនិស្សិតអាចបន្តរការបង្រៀននៅទីនោះរយៈពេលវែង។
- ដើម្បីលើកទឹកដល់គរុនិស្សិតដែលបញ្ចប់ការសិក្សានៅវិទ្យស្ថានជាតិអប់រំទៅបំរើការងារនៅខេត្តដាច់ស្រយាល ក្រសួងអប់រំអាចបង្កើតតំលៃឪកាសដល់គ្រូបង្រៀននៅខេត្តដច់ស្រយាល ដូចជាការបន្ថែមប្រាក់ម៉ោងបង្រៀន កញ្ចប់ថវិការក្នុងការរៀបចំឧបការណ៍ពិសោធន៍។
- គួរផ្តល់គ្រឿងលើកទឹកចិត្តបន្ថែមដូចជា អាហារូបករណ៍ថ្នាក់អនុបណ្ឌិត ឬបណ្ឌិតបន្ទាប់ពីបានបំរើការងាររយៈពេល ៥-១០ឆ្នាំ។ ការផ្តល់អតិភាពដល់គ្រូបង្រៀនដែលអាចបន្តការសិក្សាអាចជាគ្រឿងលើកទឹកចិត្តមួយដ៏មានប្រសិទ្ធភាពសំរាប់អោយគ្រូបង្រៀនអាចធ្វើការងាររយៈពេលយូរអង្វែង។
- គួរផ្តល់កន្លែងស្នាក់នៅសំរាប់គ្រូបង្រៀនដែលមកពីខេត្តផ្សេងជាពិសេស គ្រូបង្រៀនជាស្ត្រី។ ការផ្តល់កន្លែងស្នាក់នៅដល់គ្រូបង្រៀនថ្មីមានសារៈសំខាន់ក្នុងការទាក់ទាញអ្នកដែលខេត្តផ្សេងអាចកាត់បន្ថយការចំណាយ។
- ដើម្បីអនុវត្តកិច្ចសន្យារវាងស្ថាប័នបណ្តុះបណ្តាល និងគរុនិស្សិតអោយមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា គួរតែមិនអនុញ្ញាត្តិអោយគរុនិស្សិតដែលមានកិច្ចសន្យាជាមួយវិទ្យាស្ថានជាតិអប់រំអាចផ្ទេរទៅសាលា ឬស្ថាប័នផ្សេងទៀតទេមុនកាលកំណត់។ បើធ្វើបែបនេះគរុនិស្សិតប្រហែលជាមិនអាចគេចវេសពីកិច្ចសន្យាបានទេ។ ពួកគាត់ត្រូវតែទៅបង្រៀនតាមសាលាគោលដៅតាមកិច្ចសន្យាជាដាច់ខាត។

*វិទ្យាស្ថានជាតិអប់រំ*

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

- ដើម្បីបង្កើនចំណេះដឹង ជំនាញ និងភាពស្ទាត់ជំនាញលើការងាររបស់គរុនិស្សិត វិទ្យាស្ថានជាតិអប់រំ គួរតែបង្កើនជំនាញក្នុងការប្រើប្រាស់មន្ទីរពិសោធន៍ និងការផលិតឧបករណ៍ពិសោធន៍ក្នុងពេលបង្រៀនដល់គរុនិស្សិត។ ជាននេះទៅទៀតវិទ្យាស្ថានជាតិអប់រំ ក៏គួរតែបន្ថែមកកម្មវិធីដែលគរុនិស្សិតអាចចូលរួមហាត់ការបានច្រើន។ការផ្តល់អោយគរុនិស្សិតនូវឪកាសហាត់ការអាចជួយអោយពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ពេលចេញទៅបង្រៀន។
- វិទ្យាស្ថានជាតិអប់រំគួរតែបង្កើនកាបង្កើចំណេះដឹងរបស់គរុនិស្សិតលើសមត្ថភាពយល់ដឹង (Cognitive capacity) និង ការចូលរួមការងារសង្គម(social capacity)។ ជាងនេះទៅទៀតវិទ្យាស្ថានជាតិអប់រំក៏គួរតែពង្រឹងខ្លឹមសារបង្រៀន វិធីសាស្ត្របង្រៀន និងការតម្រង់ទិសនិងការជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវដើម្បីបង្កើនភាពស្ទាត់ជំនាញលើការងារ (competency)របស់គរុនិស្សិតពេលទៅបំរើការងារតាមសាលារៀន។
- ធ្វើការតាមដានលើការអនុវត្តកិច្ចសន្យារបស់គរុនិស្សិតដែលបណ្តុះបណ្តាលដែលទទួលអាហារូបករណ៍ពីក្រោមគម្រោងUSESDP-ADBជាមួយសាលាដែលពួកគាត់ចេញទៅបង្រៀន។ការអនុវត្តកិច្ចសន្យាមានសារៈសំខាន់ក្នុងការរក្សានិរន្តភាពនៃគម្រោង។

*មន្ទីរអប់រំ/អប់រំស្រុក*

- បង្កើនការផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ដែលមានដល់គ្រូបង្រៀន ក៏ដូចជានិស្សិតដែលបានបញ្ចប់ការសិក្សារនៅក្នុងខេត្ត/ស្រុកផ្ទាល់។
- គួរផ្តល់ការជួយជ្រុំជ្រែងដល់គ្រូបង្រៀនដែលមកថ្មីអោយមានលំនឹង ក៏ដូចជាកក់ក្តៅតាមរយៈការជួលសំរួលរកកន្លែងស្នាក់នៅ និងការរៀបចំលិខិតរដ្ឋបាល។
- តាមដាន ស្ថានភាពរស់នៅ និងការបង្រៀនរបស់គ្រូបង្រៀនដែលមកថ្មីៗដើម្បីប្រមូលពណ៌មានពីស្ថានភាពរស់នៅរបស់គាត់។

*គរុនិស្សិត*

- ត្រូវតែគោរពកិច្ចសន្យាដែលបានព្រមព្រៀងជាមួយវិទ្យាស្ថានជាតិអប់រំ អោយបានខ្ជាប់ខ្ជួន។ជាងនេះទៅទៀតគរុនិស្សិតដែលបញ្ចប់ការសិក្សាហើយទៅបង្រៀនត្រូវកាមក្រមសីលធម៌ការបង្រៀនដែលទទួលបានពីវិទ្យាស្ថានជាតិអប់រំ។
- គួរបង្កើនការយកចិត្តទុកដាក់ក្នុងការបង្រៀន និងមានការសហការណ៍ល្អជាមួយសិស្ស និងគ្រូបង្រៀនដដៃ។ ជាងនេះទៅទៀតត្រូវចេះចែករំលែកចំណេះដឹង និងជំនាញដល់គ្រូបង្រៀនដដៃនៅសាលារៀនដូចគ្នា។

*Insight: Cambodia Journal of Basic and Applied Research,* (2021)
© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

# សេចក្តីសង្ខេប

ការសិក្សាបានបង្ហាញឱ្យឃើញថា: (១) អ្នកឆ្លើយតបបានបង្ហាញការពេញចិត្តខ្ពស់លើកម្មវិធីសិក្សា លើកលែងតែសូចករទាក់ទងនឹងឱកាសហាត់ការ ពួកគាត់ពេញចិត្តត្រឹមតែមធ្យមប៉ុណ្ណោះ។ ការវិភាគ t-test ក៏បានបង្ហាញថាទស្សនៈអ្នកឆ្លើយតបជាស្ត្រីពេញចិត្តខ្លាំងជាងអ្នកឆ្លើយជាបុរសលើឱកាសដែលបានអនុវត្តលើទ្រឹស្ត្រី (P-*value*=0.003)។ (២)អ្នកឆ្លើយតបជាបុរស និងស្ត្រីមានទស្សនៈវិជ្ជមាន និងពេញចិត្តខ្លាំងលើការទទួលបានចំណេះដឹង (knowledge) ជំនាញ (skill) និងភាពស្ទាត់ជំនាញលើការងារ (competency)។ បើតាមការវិភាគដោយប្រើ Regression បានបង្ហាញថា កត្តាដែលធ្វើឱ្យចំណេះដឹងកើនរួមមាន សមត្ថភាពយល់ដឹង (Cognitive capacity) និង ការចូលរួមការងារសង្គម (social capacity) ហើយកត្តាដែលធ្វើឱ្យមានភាពស្ទាត់ជំនាញលើការងារ (competency) កើនរួមមានខ្លឹមសារបង្រៀន វិធីសាស្ត្របង្រៀន និងការតម្រង់ទិសនិងការជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវ។ (3)ដោយតម្រូវឱ្យគរុនិស្សិតទៅបង្រៀននៅខេត្តដែលបានព្រមព្រៀង អ្នកឆ្លើយតប 26.9% បានលើកឡើងថាកិច្ចសន្យានេះមិនអាចទទួលយកបានទេ ដែលក្នុងនេះមានស្ត្រី 32.6% និងបុរស 23.1%។ តាមការវិភាគដោយប្រើ Chi-square បានបង្ហាញឱ្យឃើញថាវាមានទំនាក់ទំនងរវាងការស្នើសុំកែរកុងត្រា និងការមិនអាចទទួលយកបាននូវលក្ខខណ្ឌក្នុងកុងត្រា (P-*value*=0.0000)។ (4)ក្នុង១ខែ អ្នកឆ្លើយតបទទួលបាន80ម៉ឺនរៀលពីគម្រោង និង20ម៉ឺនរៀលពីវិទ្យាស្ថានជាតិអប់រំ ប្រាក់ឧបត្ថមនេះបានគ្រប់សម្រាប់តែអាហារ (36ម៉ឺនរៀល) ឬក៏ការស្នាក់នៅ(25ម៉ឺនរៀល) តែប៉ុណ្ណោះ(P-*value*=0.0000)។ ប្រាក់ឧបត្ថមនេះវាតិចជាងការចំណាយប្រចាំខែជាក់ស្តែងខ្លាំងណាស់(94ម៉ឺនរៀលក្នុង១ខែ)(P-*value*=0.0000)។

(5) អ្នកឆ្លើយតបទទួលបានប្រាក់ខែជាមធ្យម 1.1លានរៀល ដែលមានចំនួននេះតិចជាងចំនួនដែលទទួលបាន (P-*value*=0.0000) មុនពេលចូលបង្រៀន ដែលពេលនោះពួកគាត់ទទួលបានរហូតដល់ 1.7លានរៀលឯណោះ។ តែអ្នកដែលមានប្រាក់បៀវត្តន៍ក្នុងជំឡុងពេលរៀននៅវិទ្យាស្ថានជាតិអប់រំមានចំនួនតែ 40.7% ប៉ុណ្ណោះ ។ អ្នកឆ្លើយតបដែលមានកាងារហើយ បានសម្រេចចិត្តមកធ្វើការងារជាគ្រូបង្រៀនពីព្រោះវាជាកាងារដែលមានរយៈពេលយូរអង្វែង ហើយមានស្ថានភាពការងារល្អប្រសើរ បើប្រៀបធៀបការងារមុន ភាគច្រើនជាការងារឯកជនដែលមានភាពតឹងរឹង និងមានការងាមមាញឹក។ ជារួមប្រាក់បៀវត្តន៍ដែលទទួលបានមានចំនួនច្រើនជាង ការផ្គត់ផ្គង់ការចាយវាយប្រចាំខែផ្ទាល់ខ្លួនប៉ុណ្ណោះគឺ 4.9សែនរៀល (P-value=0.0000) ដែលកំណត់ដោយក្រសួងផែនការ។ ប៉ុន្តែប្រាក់បៀវត្តន៍ដែលទទួលបានមិនអាចផ្គត់ផ្គង់ការចាយវាយប្រចាំខែសំរាប់គ្រួសារទាំងមូល(1.63លានរៀលក្នុង១ខែ)របស់ពួកគាត់បានគ្រប់គ្រាន់ដែរ(P-*value*=0.0000)។ ដើម្បីអោយគ្រូបង្រៀនដោយមិនចំណាយពេលដើម្បីធ្វើការងារ

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

ផ្សេងទៀត អ្នកឆ្លើយតបចង់បានប្រាក់បៀវត្សន៍1.6លានរៀលក្នុង១ខែ ប្រហែលជាចំនួនប្រាក់ខែដែលអាចផ្គត់ផ្គង់ការចាយវាយប្រចាំខែរបស់គ្រួសារទាំងមូលពួកគាត់បានល្មម។

## ឯកសារយោង

ADB (2018) Upper Secondary Education Sector Development Project (USESDP). Report on the follow up of the National Institute of Education (NIE) Scholarship Graduate. Phnom Penh: Asian Development Bank.

Beeby, C. E. (1980) The thesis of stages fourteen years later. *International Review of Education*, *26*(4), 451–474.

Darling-Hammond, L., & Berry, B. (1988). *The evolution of teacher policy*. Retrieved from Publications Department, The RAND Corporation website: http://eric.ed.gov/

Fata, N. (n.d.) *The status and rights of teachers: The case of Cambodia*. Retrieved from http://unescobkk.org/fileadmin/.../TeachersStatusRights.../Cambodia-NoFata-Feb15.pd.

Fennessy, D. (1998). Teachers' perceptions of the effects of in-service education and school based support on their teaching.

Grant, A. C. (2010) Tearing down the walls: creating global classrooms through online teacher preparation programs. *Distance Learning*, 7(2), 37-41.

Hargreaves, A. (2000) Four ages of professionalism and professional learning. *Teachers and Teaching: Theory and Practice*, *6*(2), 151-182.

KAPE (2016) *Discussion Note: Achieving Greater Efficiencies in Educational Development through a High and Low Cost Development Strategy,* http://kapekh.org/files/report_file/74-en.pdf.

KAPE (2016) *Discussion Note: Achieving Greater Efficiencies in Educational Development through a High and Low Cost Development Strategy,* http://kapekh.org/files/report_file/74-en.pdf.

Phin, C. (2014) Challenges of Cambodian teachers in contributing to human and social development: Are they well-trained? *International Journal of Social Science and*

© 2021 The Authors
© 2021 Research Office, Royal University of Phnom Penh

*Humanity*, *4*(5), 344-348. Retrieved from http://www.ijssh.org/papers/376-C00017.pdf.

Reimers, F. M. (2020). Building Teacher Capacity to Educate the Whole Child. Lessons from Comparative Experience. In *Empowering Teachers to Build a Better World* (pp. 1-28). Springer, Singapore.

Tan, C., & Ng, P. (2012) A critical reflection of teacher professionalism in Cambodia. *Asian Education and Development Studies*, 1(2), 124–138.

Tan, C., & Ng, P. T. (2012) A critical reflection of teacher professionalism in Cambodia. *Education and Development Studies*, *1*(2), 124-138.

Tatto, M. T. (2008). Teacher policy: A framework for comparative analysis. *Prospects*, *38*(4), 487-508. Retrieved from https://www.researchgate.net/profile/Maria_Tatto/publication/44840491_Teacher_policy_a_framework_for_comparative_analysis/links/02e7e51e17b50b87a1000000.pdf.

UNESCO (2014). *EFA Global Monitoring Report 2013/14: Teaching and learning: Achieving quality for all*. Paris: UNESCO.

West, E. & Jones, P. (2007) A framework for planning technology used in teacher education programs that serve rural communities. *Rural Special Education Quarterly*, 26(4), 3-15.